ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់ ស្តីពី ជលផល

ឆ្នាំ ២០២៥

ច្បាប់ស្តីពីជលផល ឆ្នាំ២០២៥

## ១៣- ឧបករណ៍នេសាទសមុទ្រខ្នាតធំ

| ល.រ. | ឈ្មោះឧបករណ៍នេសាទ | ចំនួន | ប្រវែង/ក្រឡា | ផ្សេងៗ |
|---|---|---|---|---|
| ១ | អួនអូស | ១ចូរ | - ក្រឡាថ្នក់កន្ទុយអួន ១,៥ស.ម.ឡើង | - នាវានេសាទប្រវែងលើស២៤ម.ធ្វើនេសាទសមុទ្រក្រៅ |
| ២ | អួនទិត | | - ប្រវែងលើស៥០០ម.<br>- ក្រឡា៣ស.ម.ឡើង | - អនុញ្ញាតឱ្យនេសាទនៅសមុទ្រក្រៅ |
| ៣ | អួនហ៊ុមរួមផ្សំភ្លើង | | - ប្រវែងលើស៥០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | - អនុញ្ញាតឱ្យនេសាទនៅសមុទ្រក្រៅ |
| ៤ | អួនកាកឹម | | - ប្រវែងលើស៥០០ម.<br>- ក្រឡា០,៥ស.ម.ឡើង | - អនុញ្ញាតឱ្យនេសាទនៅសមុទ្រក្រៅ |
| ៥ | អួនអូសគូ | | - ក្រឡាថ្នក់កន្ទុយអួន ១,៥ស.ម.ឡើង | - អនុញ្ញាតឱ្យនេសាទនៅសមុទ្រក្រៅ |

## ២- ប្រភេទនាវានេសាទនិងនាវាពាក់ព័ន្ធនឹងការនេសាទសមុទ្រ

### ក- ប្រភេទនាវានេសាទសមុទ្រ

| ល.រ. | ប្រភេទនាវា | ប្រវែងនាវានេសាទ | ផ្សេងៗ |
|---|---|---|---|
| ១ | នាវាខ្នាតតូច | ខ្លីជាង១២ម. | លើកលែងនាវានេសាទអួនអូស ឈិបយន្ត ឬឈ្នាងអូសគ្រែង គ្រំ ឬលៀស |
| ២ | នាវាខ្នាតមធ្យម | ចាប់ពី១២ម. ដល់២៤ម. | នាវានេសាទអួនអូស ឈិបយន្ត ឬឈ្នាងអូសគ្រែង គ្រំ ឬលៀសកម្លាំងម៉ាស៊ីនតូចជាង៥០០សេះ |
| ៣ | នាវាខ្នាតធំ | លើស២៤ម. | នាវានេសាទអួនអូសកម្លាំងម៉ាស៊ីនលើស៥០០សេះ |

### ខ- ប្រភេទនាវាពាក់ព័ន្ធនឹងការនេសាទសមុទ្រ

| ល.រ. | ប្រភេទនាវា | ប្រវែងនាវាពាក់ព័ន្ធនឹងការនេសាទ | ផ្សេងៗ |
|---|---|---|---|
| ១ | នាវាខ្នាតតូច | ខ្លីជាង១២ម. | |
| ២ | នាវាខ្នាតមធ្យម | ចាប់ពី១២ម. ដល់២៤ម. | |
| ៣ | នាវាខ្នាតធំ | លើស២៤ម. | |

**សម្គាល់:** ម. = ម៉ែត្រ, ស.ម. = សង់ទីម៉ែត្រ



នស/រកម/០៦២៥/ ០២៤

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៣ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

| | | | | |
|---|---|---|---|---|
| ៣៨ | លបត្រីតុកកែ | លើស៣០លប | - ក្រឡា៦ស.ម.ឡើង | |
| ៣៩ | លបប្រីសច្រើន ឬកន្ទុយកណ្ដុរ | លើស៣០លប | - ក្រឡា៣ស.ម.ឡើង | |
| ៤០ | អួនអូស | ១ចូរ | - ក្រឡាថ្នក់កន្ទុយអួន ១,៥ស.ម.ឡើង | - នាវានេសាទប្រវែងខ្លីជាង១២ម. អាចធ្វើនេសាទក្នុងកន្លែងនេសាទតាមឆ្នេរ ចំពោះតែទីតាំងដែលត្រូវបានកំណត់ជាក់លាក់ - នាវានេសាទប្រវែងចាប់ពី១២ម. ដល់២៤ម. ធ្វើនេសាទសមុទ្រក្រៅ |
| ៤១ | អួនទិត | | - ប្រវែងមិនលើស៥០០ម. - ក្រឡា៣ស.ម.ឡើង | អនុញ្ញាតឱ្យនេសាទសមុទ្រក្រៅ |
| ៤២ | អួនហ៊ុមរួមផ្សំភ្លើង | | - ប្រវែងមិនលើស៥០០ម. - ក្រឡា៣,៥ស.ម.ឡើង | អនុញ្ញាតឱ្យនេសាទសមុទ្រក្រៅ |
| ៤៣ | អួនកាកឹម | | - ប្រវែងមិនលើស៥០០ម. - ក្រឡា០,៥ស.ម.ឡើង | អនុញ្ញាតឱ្យនេសាទសមុទ្រក្រៅ |
| ៤៤ | អួនហ៊ុមកៀនច្រាំង | | - ប្រវែងលើស២០០ម. - ក្រឡា៣ស.ម.ឡើង | |
| ៤៥ | អួនខ្ញូវឬមងខ្ញូវ | | - ប្រវែងលើស២០០ម. - ក្រឡា៣ស.ម.ឡើង | |
| ៤៦ | អួនកេវឬមងកេវ | | - ប្រវែងលើស២០០ម. - ក្រឡា៣ស.ម.ឡើង | |
| ៤៧ | អួនត្រីកាឡេងគេង | | - ប្រវែងលើស២០០ម. - ក្រឡា១,៥ស.ម.ឡើង | |

| | | | | |
|---|---|---|---|---|
| ១៩ | មងត្រីផ្ទោង | | - ប្រវែងលើស២០០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ២០ | មងត្រីកន្ធាំង | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៤ស.ម.ឡើង | |
| ២១ | មងក្តាម | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |
| ២២ | មងប៉ាកាំង<br>ឬបង្កងកណ្តូប | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |
| ២៣ | មងត្រីកាម៉ុង | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ២៤ | មងត្រីកន្ទុយរឹង | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៤ស.ម.ឡើង | |
| ២៥ | មងត្រីកាវ៉ាវ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៧ស.ម.ឡើង | |
| ២៦ | មងត្រីបេកា | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |
| ២៧ | មងត្រីសំប៉ាន | | - ប្រវែងលើស២០០០ម.<br>- ក្រឡា១០ស.ម.ឡើង | |
| ២៨ | មងត្រីគួន | | - ប្រវែងលើស២០០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ២៩ | អួនត្រីស | | - ប្រវែងលើស២០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ៣០ | មងបង្គា៣ជាន់ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៣១ | មងបង្គា១ជាន់ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៣២ | មងហ៊ុម | | - ប្រវែងលើស១០០ម.<br>ដល់២០០ម.<br>- ក្រឡា៣ស.ម.ឡើង | |
| ៣៣ | លបមឹក | លើស១០០លប | - ក្រឡា៦ស.ម.ឡើង | |
| ៣៤ | លបក្តាម | លើស១០០០លប | - ក្រឡា៦ស.ម.ឡើង | |
| ៣៥ | លបបង្គា | លើស១០០លប | | |
| ៣៦ | លបខ្យង | លើស១០០លប | | |
| ៣៧ | លបត្រី | លើស៣០លប | - ក្រឡា៦ស.ម.ឡើង | |

x

# ច្បាប់
# ស្តីពី
# ជលផល

## ១២- ឧបករណ៍នេសាទសមុទ្រខ្នាតមធ្យម

| ល.រ. | ឈ្មោះឧបករណ៍នេសាទ | ចំនួន | ប្រវែង/ក្រឡា | ផ្សេងៗ |
|---|---|---|---|---|
| ១ | សន្ទូចរនងត្រី | លើស១៥០០ផ្លែ | | |
| ២ | សន្ទូចរនងបបែល | លើស១៥០០ផ្លែ | | |
| ៣ | សន្ទូចរនងមឹក | លើស១៥០០ផ្លែ | | |
| ៤ | រនងផ្អាក់មឹក | លើស១៥០០គ្រាប់ | | |
| ៥ | ឈិបយន្ត | | - ក្រឡា២ស.ម.ឡើង | |
| ៦ | ឈ្នាងអូសគ្រែង គ្រុំ ឬលៀស | | - មាត់ឈ្នាងមិនលើស១,២ម.<br>- ក្រឡា២ស.ម.ឡើង | |
| ៧ | ឈ្នាងអូសគ្រំក្រឡាហូល | | - មាត់ឈ្នាងមិនលើស១,២ម.<br>- ក្រឡា១,២ស.ម.ឡើង | |
| ៨ | មងត្រីចម្រុះ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៩ | មងត្រីក្បក | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ១០ | មងត្រីឆ្លង់ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា១០ស.ម.ឡើង | |
| ១១ | មងត្រីក្លុក | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |
| ១២ | មងត្រីអណ្តាតឆ្កែ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៤ស.ម.ឡើង | |
| ១៣ | មងត្រីចាប | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៦ស.ម.ឡើង | |
| ១៤ | មងបបែល | | - ប្រវែងលើស២០០០ម.<br>- ក្រឡា១៥ស.ម.ឡើង | |
| ១៥ | មងត្រីព្រលួស | | - ប្រវែងលើស២០០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ១៦ | មងត្រីប្រខុប ឬត្រីតាម៉យ | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ១៧ | មងត្រី[illegible]ប៉ាស់ ឬត្រីដូ[illegible] | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៤ស.ម.ឡើង | |
| ១៨ | មងត្រី[illegible] | | - ប្រវែងលើស២០០០ម.<br>- ក្រឡា៣ស.ម.ឡើង | |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | | | |
|---|---|---|---|---|
| ៤២ | មងត្រីសំប៉ាន | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា១០ស.ម.ឡើង | |
| ៤៣ | មងត្រីគូន | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ៤៤ | អួនត្រីស | | - ប្រវែងមិនលើស២០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ៤៥ | អួនត្រីកាឡេងតេង | | - ប្រវែងមិនលើស២០០ម.<br>- ក្រឡា១,៥ស.ម.ឡើង | |
| ៤៦ | មងបង្គា៣ជាន់ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៤៧ | មងបង្គា១ជាន់ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៤៨ | មងហ៊ុម | | - ប្រវែងមិនលើស១០០ម.<br>- ក្រឡា៣ស.ម.ឡើង | |
| ៤៩ | លបមឹក | មិនលើស១០០លប | - ក្រឡា៦ស.ម.ឡើង | |
| ៥០ | លបក្តាម | មិនលើស១០០០លប | - ក្រឡា៦ស.ម.ឡើង | |
| ៥១ | លបបង្គា | មិនលើស១០០លប | | |
| ៥២ | លបខ្យង | មិនលើស១០០លប | | |
| ៥៣ | លបត្រី | មិនលើស៣០លប | - ក្រឡា៦ស.ម.ឡើង | |
| ៥៤ | លបត្រីតុកកែ | មិនលើស៣០លប | - ក្រឡា៦ស.ម.ឡើង | |
| ៥៥ | លបប្រឹសច្រើនឬ<br>លបកន្ទុយកណ្តុរ | មិនលើស៣០លប | - ក្រឡា៣ស.ម.ឡើង | |
| ៥៦ | អួនហ៊ុមកៀនច្រាំង | | - ប្រវែងមិនលើស២០០ម.<br>- ក្រឡា៣ស.ម.ឡើង | |
| ៥៧ | អួនខ្ចូវឬមងខ្ចូវ | | - ប្រវែងមិនលើស២០០ម.<br>- ក្រឡា៣ស.ម.ឡើង | |
| ៥៨ | អួនកេវឬមងកេវ | | - ប្រវែងមិនលើស២០០ម.<br>- ក្រឡា៣ស.ម.ឡើង | |



## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព សំដៅលើកកម្ពស់សន្តិសុខស្បៀងនិងសេដ្ឋកិច្ចជាតិ ព្រមទាំងធានាដល់ការការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជានេសាទ សហគមន៍នេសាទ វារីវប្បករ និងអាជីវករដែលធ្វើអាជីវកម្មផល ផលិតផលជលផល។

**មាត្រា២ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើធនធានជលផល តំបន់គ្រប់គ្រងជលផល ប្រតិបត្តិករនិងសកម្មភាពពាក់ព័ន្ធជលផល នៅក្នុងដែនអធិបតេយ្យនិងដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការធ្វើនេសាទក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ស្របតាមអនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតុបករណ៍អន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១ នៃច្បាប់នេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍជលផល ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍជលផលដែលស្ថិតក្នុងតំបន់ការពារធម្មជាតិត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមបរិស្ថាននិងធនធានធម្មជាតិ។

រាជរដ្ឋាភិបាលអាចកំណត់អំពីតួនាទី ការទទួលខុសត្រូវ និងកិច្ចសហការជាក់លាក់សម្រាប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងវិស័យជលផលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៥ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវមានអង្គភាពជំនាញទទួលបន្ទុកជលផលជាសេនាធិការ ដែលអង្គភាពជំនាញនេះកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ .-**

រាជរដ្ឋាភិបាល អាចផ្ទេរមុខងារនិងការទទួលខុសត្រូវជាក់លាក់មួយចំនួនក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍជលផលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍជលផលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមបទប្បញ្ញត្តិនានាជាធរមាន។

## ជំពូកទី៣
## និរន្តរភាពនៃការគ្រប់គ្រងជលផល

**មាត្រា៧ .-**

ការគ្រប់គ្រងជលផល ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម៖

១- គ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ដោយផ្អែកលើព័ត៌មានទិន្នន័យវិទ្យាសាស្ត្រ។

២- ប្រើប្រាស់និងបែងចែកធនធានជលផលប្រកបដោយសមធម៌។

៣- លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយតម្លាភាពនិងបរិយាបន្ន។

៤- លើកកម្ពស់ការអភិវឌ្ឍវារីវប្បកម្មនៅតំបន់ដែលមានសក្តានុពល។

៥- គោរពកិច្ចព្រមព្រៀងនិងលិខិតុបករណ៍អន្តរជាតិនិងថ្នាក់តំបន់ពាក់ព័ន្ធផ្សេងទៀត ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

៦- អនុវត្តលក្ខខណ្ឌការងារសមស្របក្នុងការងារជលផលនៅលើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ ដើម្បីការពារពលករ ប្រឆាំងនឹងការជួញដូរមនុស្សឬប្រើពលករដោយបង្ខំ។

៧- ធានាសុវត្ថិភាពចំណីអាហារ។

៨- លើកកម្ពស់ជីវភាពប្រជានេសាទឱ្យបានល្អប្រសើរ។

**មាត្រា៨ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ត្រូវទទួលបានថវិកាចំណូលពីវិស័យជលផល ជាអាទិភាពតាមនីតិវិធីហិរញ្ញវត្ថុ សម្រាប់បម្រើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍជលផលប្រកបដោយនិរន្តរភាព។

**មាត្រា៩ .-**

ត្រូវកំណត់យកថ្ងៃទី១ ខែកក្កដា ជាទិវាមច្ឆជាតិ។

## ជំពូកទី៤
## តំបន់គ្រប់គ្រងជលផល

**មាត្រា១០ .-**

តំបន់គ្រប់គ្រងជលផល រួមមានដែនដីលិចទឹកអចិន្ត្រៃយ៍ នាទីព្រៃលិចទឹក នាទីព្រៃកោងកាង ដែនដីលិចទឹកនារដូវជំនន់ឡើង និងដែនដីដែលទទួលរបបទឹកជោរ នាចពីសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារប្រព័ន្ធអេកូឡូស៊ីជលផល។

ដែនដីលិចទឹកអចិន្ត្រៃយ៍ ជាអាទិ៍សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក។

ដែនដីលិចទឹកនារដូវជំនន់ឡើង ជាអាទិ៍វាលភក់ ត្រពាំង រណ្ដៅ ទីជម្រកសំខាន់ តំបន់ដីសើម ទំនាបលិចទឹក។

ដែនដីដែលទទួលរបបទឹកជោរ នាចពីសមុទ្រ ជាអាទិ៍ឆ្នេរខ្សាច់ ឆ្នេរថ្ម។

**មាត្រា១១ .-**

តំបន់គ្រប់គ្រងជលផលអាចគ្របដណ្ដប់លើដីសាធារណៈនិងដីកម្មសិទ្ធិឯកជននារដូវជំនន់ឡើង ប៉ុន្តែការគ្រប់គ្រងធនធានជលផលមិនប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិឯកជននោះឡើយ។

តំបន់គ្រប់គ្រងជលផលចែកជាតំបន់គ្រប់គ្រងជលផលទឹកសាបនិងតំបន់គ្រប់គ្រងជលផលសមុទ្រ។



| | | | | |
|---|---|---|---|---|
| ២៤ | មងត្រីក្បក | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ២៥ | មងត្រីឆ្កង់ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា១០ស.ម.ឡើង | |
| ២៦ | មងត្រីក្អុក | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៩ស.ម.ឡើង | |
| ២៧ | មងត្រីអណ្ដាតឆ្កែ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៥,៥ស.ម.ឡើង | |
| ២៨ | មងត្រីចាប | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៦ស.ម.ឡើង | |
| ២៩ | មងបបែល | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា១៥ស.ម.ឡើង | |
| ៣០ | មងត្រីព្រលួស | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ៣១ | មងត្រីប្រខុប<br>ឬត្រីកាម៉យ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៣២ | មងត្រីកាប៉ាស់<br>ឬត្រីដូរអង្ករ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៤ស.ម.ឡើង | |
| ៣៣ | មងត្រីក្សាន្ត | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៣ស.ម.ឡើង | |
| ៣៤ | មងត្រីផ្ទោង | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា២,៥ស.ម.ឡើង | |
| ៣៥ | មងត្រីកន្ទាំង | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៤ស.ម.ឡើង | |
| ៣៦ | មងក្ដាម | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |
| ៣៧ | មងប៉ាកាំង<br>ឬបង្កងកណ្ដូប | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |
| ៣៨ | មងត្រីកាម៉ុង | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៣,៥ស.ម.ឡើង | |
| ៣៩ | មងត្រីកន្ទុយរឹង | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៤,៨ស.ម.ឡើង | |
| ៤០ | មងត្រីកាវ | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៧ស.ម.ឡើង | |
| ៤១ | មងត្រីបេកា | | - ប្រវែងមិនលើស២០០០ម.<br>- ក្រឡា៨ស.ម.ឡើង | |

### ខ- ឧបករណ៍នេសាទសមុទ្រ

### ខ១- ឧបករណ៍នេសាទសមុទ្រខ្នាតតូច

| ល.រ. | ឈ្មោះឧបករណ៍នេសាទ | ចំនួន | ប្រវែង/ក្រឡា | ផ្សេងៗ |
|---|---|---|---|---|
| ១ | សាង | | | |
| ២ | សម | | | |
| ៣ | ច្បូក | | | |
| ៤ | កង្វារ | | | |
| ៥ | ព្រួញបាញ់ | | | មិនអនុញ្ញាតក្នុងតំបន់ផ្កាថ្ម/តំបន់ថ្មប៉ប្រះទឹក |
| ៦ | ឈិបរុញដោយដៃ | | ក្រឡា១,៥ស.ម.ឡើង | |
| ៧ | ឈិបរុញគីឬរង្វះគី | | | ប្រើដោយដៃ |
| ៨ | ថ្នូងដងគី | | | ប្រើដោយដៃ |
| ៩ | ថ្នូងដងមឹក | | | ប្រើដោយដៃ |
| ១០ | សំណាញ់ | | ក្រឡា១,៥ស.ម.ឡើង | |
| ១១ | អញ្ចង | | ក្រឡា១,៥ស.ម.ឡើង | |
| ១២ | នោស់ឬឈ្នាងអូសគ្រែងឈាម | | ក្រឡា២ស.ម.ឡើង | ប្រើដោយដៃ |
| ១៣ | ផ្ទូងផាង | | ក្រឡា១,៥ស.ម.ឡើង | |
| ១៤ | ឈ្នក់ក្ដាម | | ក្រឡា១,៥ស.ម.ឡើង | |
| ១៥ | លបរួមផ្សំរបាំងព្រួលឬសាច់អួន | | ចន្លោះត្រៀមមួយទៅត្រៀមមួយចាប់ពី១,៥ស.ម.ឡើង ឬសាច់អួន២,៥ស.ម.ឡើង | |
| ១៦ | សន្ទូច | | | |
| ១៧ | សន្ទូចមឹក | | | |
| ១៨ | សន្ទូចត្រីបេកា | | | |
| ១៩ | សន្ទូចរនងត្រី | មិនលើស១៥០០ផ្លែ | | |
| ២០ | សន្ទូចរនងបបែល | មិនលើស១៥០០ផ្លែ | | |
| ២១ | សន្ទូចរនងមឹក | មិនលើស១៥០០ផ្លែ | | |
| ២២ | រនងផ្កាក់មឹក | មិនលើស១៥០០គ្រាប់ | | |
| ២៣ | មងត្រីបម្រុះ | | -ប្រវែងមិនលើស២០០០ម. -ក្រឡា៣,៥ស.ម.ឡើង | |



**មាត្រា១២ .-**

តំបន់គ្រប់គ្រងជលផលទឹកសាប ត្រូវបានកំណត់ដូចខាងក្រោម៖

១- កន្លែងនេសាទសាធារណៈ។

២- កន្លែងនេសាទកំណត់ឧបករណ៍នេសាទដាក់លាក់។

៣- កន្លែងសហគមន៍នេសាទ។

៤- កន្លែងអភិវឌ្ឍវារីវប្បកម្ម។

៥- កន្លែងអភិរក្សជលផល។

៦- កន្លែងអភិរក្សនិងការពារសត្វផ្សោតទន្លេមេគង្គ។

**មាត្រា១៣ .-**

តំបន់គ្រប់គ្រងជលផលសមុទ្រ ត្រូវបានកំណត់ដូចខាងក្រោម៖

១- កន្លែងនេសាទសាធារណៈ។

២- កន្លែងសហគមន៍នេសាទ។

៣- កន្លែងអភិវឌ្ឍវារីវប្បកម្ម។

៤- កន្លែងអភិរក្សជលផល។

**មាត្រា១៤ .-**

នីតិវិធីនិងលក្ខណវិនិច្ឆ័យនៃការបង្កើតឬរំសាយតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយអនុក្រឹត្យ។

ការបង្កើតឬរំសាយកន្លែងនីមួយៗនៃតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា១៥ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអនុញ្ញាតឱ្យប្រើតំបន់គ្រប់គ្រងជលផលទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះដល់បុគ្គល ដើម្បីធ្វើការនេសាទ អាជីវកម្មលើផល ផលិតផលជលផល និងវារីវប្បកម្ម ព្រមទាំងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រលើធនធានជលផល។

រាល់ការប្រើប្រាស់តំបន់គ្រប់គ្រងជលផល ដើម្បីគោលបំណងក្រៅវិស័យជលផល ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច។

**មាត្រា១៦ .-**

អង្គភាពជំនាញទទួលបន្ទុកជលផល អាចស្នើសុំចុះបញ្ជីដីប្រភេទណាមួយនៃតំបន់គ្រប់គ្រងជលផលជាទ្រព្យសម្បត្តិរដ្ឋ។

ការផ្ដល់កម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចពាក់ព័ន្ធដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៧ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិរៀបចំ ចាត់ចែង និងគ្រប់គ្រងតំបន់គ្រប់គ្រងជលផលដើម្បីអភិវឌ្ឍជាតំបន់ទេសចរណ៍ជលផល ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជនពាក់ព័ន្ធ។

ការបង្កើតនិងការគ្រប់គ្រងតំបន់ទេសចរណ៍ជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៥
## ការការពារនិងការអភិរក្សធនធានជលផល

**មាត្រា១៨ .-**

ហាមឃាត់សកម្មភាពក្នុងកន្លែងអភិរក្សជលផលដូចខាងក្រោម៖

១- ការធ្វើនេសាទគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ធ្វើការពិសោធនិងការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល។

២- ការធ្វើនាវាចរណ៍ឆ្លងកាត់ដោយរៀបចំឧបករណ៍នេសាទដែលមានលក្ខណៈប៉ុនប៉ងធ្វើការនេសាទ ឬសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់ធនធានជលផល។

៣- ការតាំងទីលំនៅថ្មីដែលស្ថិតនៅតិចជាង២(ពីរ)គីឡូម៉ែត្រពីព្រំប្រទល់កន្លែងអភិរក្សជលផល លើកលែងតែទីស្នាក់ការរបស់មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សម្រាប់គោលបំណងអនុវត្តច្បាប់។

**មាត្រា១៩ .-**

ហាមឃាត់សកម្មភាពក្នុងកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គដូចខាងក្រោម៖

១- ការធ្វើនេសាទគ្រប់ប្រភេទ។

២- ការធ្វើវារីវប្បកម្ម។

៣- ការធ្វើនាវាចរណ៍ឆ្លងកាត់ដែលមានឧបករណ៍ប៉ុនប៉ងធ្វើការនេសាទ។

៤- ការធ្វើនាវាចរណ៍ដែលមានល្បឿនលើសពី៣០(សាមសិប)គីឡូម៉ែត្រក្នុងមួយម៉ោង។

៥- ការតាំងទីលំនៅថ្មី។

៦- ការធ្វើសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់សត្វផ្សោត។

ហាមឃាត់ការធ្វើនេសាទក្នុងកន្លែងការពារសត្វផ្សោត ដោយប្រើឧបករណ៍នេសាទខ្នាតមធ្យមនិងខ្នាតធំ លើកលែងតែការធ្វើនេសាទដោយឧបករណ៍នេសាទខ្នាតតូច។

ប្រភេទឧបករណ៍នេសាទខ្នាតតូចដែលអនុញ្ញាតឱ្យធ្វើការនេសាទក្នុងកន្លែងការពារសត្វផ្សោត ត្រូវបានកំណត់ស្របតាមមាត្រា២៨នៃច្បាប់នេះ។

**មាត្រា២០ .-**

ហាមឃាត់សកម្មភាពនិងការប្រើឧបករណ៍នេសាទដូចខាងក្រោម៖

១- ឧបករណ៍ឆក់ គ្រឿងផ្ទុះ ឬសារធាតុពុល។

២- ឧបករណ៍នេសាទមុជចាក់ឬមុជបាញ់ត្រីនៅក្នុងអន្លង់នៃតំបន់គ្រប់គ្រងជលផលទឹកសាបឬតំបន់ផ្កាថ្ម តំបន់ថ្មប៉ប្រះទឹកនៃតំបន់គ្រប់គ្រងជលផលសមុទ្រ។

៣- ការធ្វើនេសាទរួមផ្សំបំពង់ខ្យល់ឬម៉ាស៊ីនខ្យល់។

៤- ឧបករណ៍នេសាទស្បៃមុង លើកលែងឧបករណ៍នេសាទគីឬថ្នង។

៥- ការធ្វើនេសាទដោយប្រើឧបករណ៍អួនអូសសេះសមុទ្រ។

៦- ការប្រើឧបករណ៍នេសាទបង្កើតថ្មីឬឧបករណ៍នេសាទដែលគ្មានក្នុងឧបសម្ព័ន្ធទី២នៃច្បាប់នេះ ឬគ្មានក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬរបៀបនេសាទបែបថ្មីដែលបំផ្លាញធនធានជលផលឬប្រព័ន្ធអេកូឡូស៊ីជលផល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



**ក៣- ឧបករណ៍នេសាទទឹកសាបខ្នាតធំ**

| ល.រ. | ឈ្មោះឧបករណ៍នេសាទ | ប្រវែង/ក្រឡា | ផ្សេងៗ |
|---|---|---|---|
| ១ | ដាយត្រី | - បណ្ដោយប្រវែង១២០ម. ទទឹងមាត់ប្រវែង២៧ម.<br>- ក្រឡាប្រដេញពីធំទៅតូចរហូតដល់ថ្នក់កន្ទុយដាយ | |
| ២ | ដាយត្រីលេញ | - បណ្ដោយប្រវែង១០០ម. ទទឹងមាត់ប្រវែង២៧ម.<br>- ក្រឡាប្រដេញពីធំទៅតូចរហូតដល់ថ្នក់កន្ទុយដាយ | |
| ៣ | ដាយបង្កង | - បណ្ដោយប្រវែង៣០ម. ទទឹងមាត់ប្រវែង៨ម.<br>- ក្រឡាប្រដេញចាប់ពី៤ស.ម.ចុះ ដល់ថ្នក់កន្ទុយដាយ | |
| ៤ | ធ្នស់ | ចន្លោះគ្រៀមមួយទៅគ្រៀមមួយចាប់ពី១,៥ស.ម. ឡើងឬសាច់អួន២,៥ស.ម.ឡើង | |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ក២- ឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម

| ល.រ. | ឈ្មោះឧបករណ៍នេសាទ | ប្រវែង/ក្រឡា | ផ្សេងៗ |
|---|---|---|---|
| ១ | នាម | ក្រឡា១,៥ស.ម.ឡើង | - អនុញ្ញាតឱ្យធ្វើនេសាទតែនៅទន្លេមេគង្គនិងទន្លេបាសាក់<br>- កម្លាំងម៉ាស៊ីនមិនលើស២០សេះ |
| ២ | ចៃប៉ា | ក្រឡា១,៥ស.ម.ឡើង | កម្លាំងម៉ាស៊ីនមិនលើស២០សេះ និងមិនប្រើខ្យល់រួមផ្សំ |
| ៣ | ជន | ក្រឡា១,៥ស.ម.ឡើង | - អនុញ្ញាតឱ្យធ្វើនេសាទតែនៅទន្លេមេគង្គនិងទន្លេបាសាក់<br>- កម្លាំងម៉ាស៊ីនមិនលើស២០សេះ |
| ៤ | ម៉ាញ់ | ក្រឡា១,៥ស.ម.ឡើង | - អនុញ្ញាតឱ្យធ្វើនេសាទតែនៅទន្លេមេគង្គ<br>- កម្លាំងម៉ាស៊ីនមិនលើស២០សេះ |
| ៥ | អួនហ៊ុម | ក្រឡា១,៥ស.ម.ឡើង<br>- ប្រវែងមិនលើស៦០០ម. ក្នុងបឹងទន្លេសាប<br>- ប្រវែងមិនលើស៣០០ម. ក្រៅបឹងទន្លេសាប | កម្លាំងម៉ាស៊ីនមិនលើស៣០សេះ |
| ៦ | អួនព្រយុង | - ក្រឡា១,៥ស.ម.ឡើង<br>- ប្រវែងមិនលើស៣០០ម. | កម្លាំងម៉ាស៊ីនមិនលើស៣០សេះ |
| ៧ | លប លបណប្ញាវ ឬលូ ឬឡុក | ចន្លោះត្រៀមមួយទៅត្រៀមមួយចាប់ពី១,៥ស.ម.ឡើងឬសាច់អួន២,៥ស.ម.ឡើង<br>-រួមផ្សំរបាំងព្រួលឬសាច់អួនប្រវែងលើស២៥០ម. ដល់៥០០ម.ក្នុងរដូវបើកនេសាទនៅតំបន់បឹងទន្លេសាប<br>-រួមផ្សំរបាំងព្រួលឬសាច់អួនប្រវែងលើស១៥០ម. ដល់២៥០ម.ក្នុងរដូវបើកនេសាទនៅតំបន់ក្រៅបឹងទន្លេសាប | |
| ៨ | ស្នួងអូសប្រុញ ខ្មៅ ឬរៀស | ក្រឡា២,៥ស.ម.ឡើង | ប្រើម៉ាស៊ីនរួមផ្សំមិនលើស២៤សេះ |



៧- ការផ្លាស់ប្តូរ ការរំកិល ការដកកប់ ឬការបំផ្លាញបង្គោលព្រំប្រទល់កន្លែងណាមួយនៃតំបន់គ្រប់គ្រងជលផល។

៨- ការគាស់ ការកកាយយកក្រួស ថ្ម ដី ខ្សាច់ ឬរ៉ែ ក្នុងកន្លែងអភិរក្សជលផល។

៩- ការប្រើឧបករណ៍នេសាទនិងមធ្យោបាយគ្រប់ប្រភេទ ខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត។

១០- ការផ្តល់ព័ត៌មានមិនត្រឹមត្រូវឬមិនពេញលេញក្នុងពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារផ្សេងទៀតដែលមានចែងក្នុងច្បាប់នេះ។

១១- សកម្មភាពដែលបំផ្លាញធនធានជលផល ឬបង្កការខូចខាតដល់បរិស្ថាន ឬប្រព័ន្ធអេកូឡូស៊ីជលផល។

**មាត្រា២១ .-**

សកម្មភាពដូចខាងក្រោមអាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល៖

១- ការចាប់ ការទិញ ការលក់ ការធ្វើសន្និធិ ឬការដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រំ កូនលៀស កូនខ្យង កូនខ្ចៅ ឬកូនឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ។

២- ការចាប់ ការទិញ ការលក់ ការប្រមូលផល ការកែច្នៃ ការធ្វើសន្និធិ ការដឹកជញ្ជូន ការនាំចេញ ឬការនាំចូល នូវប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់។

៣- ការទិញ ការលក់ ឬការធ្វើសន្និធិ ពពួកសម្បកខ្យង ខ្ចៅ ឬគ្រំ តាំងលម្អដែលជាប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់។

៤- ការប្រមូល ការដកហូត ការទិញ ការលក់ ការធ្វើសន្និធិ ឬការដឹកជញ្ជូនផ្កាថ្ម។

៥- ការធ្វើនេសាទដោយឧបករណ៍អួនអូសគូ ឬអួនហ៊ុមរួមផ្សំភ្លើង ដែលធ្វើឱ្យត្រីឬវារីសត្វកុំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ។

៦- ការដឹកជញ្ជូន ការទិញ ការលក់ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ដែលបានពីវារីវប្បកម្ម។

ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២ .-**

ហាមឃាត់ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឈិបយន្តទឹកសាប អួនអូសទឹកសាប ឧបករណ៍ឆក់ត្រី ឬឧបករណ៍នេសាទស្បៃមុង លើកលែងឧបករណ៍នេសាទគីឬថ្នង។

ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយទៅក្នុងតំបន់គ្រប់គ្រងជលផល នូវកាកសំណល់រឹងឬរាវ ឬសារធាតុពុលដែលជះឥទ្ធិពលអវិជ្ជមានដល់វារីសត្វឬវារីរុក្ខជាតិ ដែលនាំឱ្យមានការបំពុលក្នុងតំបន់គ្រប់គ្រងជលផលដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងកិច្ចព្រមព្រៀងឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

**មាត្រា២៣ .-**

ការធ្វើទំនប់ឬរបាំងកាត់ ការចាក់ឬការលុបសមុទ្រ ទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ ឬអាងទឹកធម្មជាតិ ឬការជីកប្រឡាយ រណ្តៅ ឬស្រះទ្រង់ទ្រាយធំ ឬការសាងសង់សំណង់ថ្មីនានា ឬការបូមទឹកដែលបង្កមហន្តរាយដល់ធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផលត្រូវមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច។

**មាត្រា២៤ .-**

ប្រជាពលរដ្ឋ សហគមន៍នេសាទ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរគ្រប់ថ្នាក់ ត្រូវមានករណីយកិច្ចចូលរួមថែរក្សានិងការពារជម្រកមច្ឆជាតិ បង្ការនិងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកនិងព្រៃកោងកាង។

គោលការណ៍ណែនាំក្នុងការការពារភ្លើងឆេះព្រៃលិចទឹកនិងព្រៃកោងកាង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៥ .-**

តំបន់លិចទឹកក្នុងនាទីព្រៃលិចទឹកនិងព្រៃកោងកាង ត្រូវការពារសម្រាប់ដាំឬរក្សាទុកឱ្យដុះព្រៃឡើងវិញ ដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផល។

**មាត្រា២៦ .-**

ហាមឃាត់សកម្មភាពដូចខាងក្រោម៖

១- ការទន្ទ្រាន ហ៊ុមព័ទ្ធកាន់កាប់ដីក្នុងនាទីព្រៃលិចទឹកឬព្រៃកោងកាង។

២- ការផ្តល់កម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងនាទីព្រៃលិចទឹកឬព្រៃកោងកាងដែលមិនអនុវត្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា១៦នៃច្បាប់នេះ។

៣- ការដុត ការកាប់ឆ្ការ ការគាស់រាន ការឈូសឆាយ ឬការផ្តួលរំលំព្រៃលិចទឹកឬព្រៃកោងកាង។

៤- ការបន្សល់ទុកនូវដើមហេតុដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកឬព្រៃកោងកាង។

៥- ការធ្វេសប្រហែស ការខ្ជីខ្ជាមិនប្រុងប្រយ័ត្ន ឬការមិនគោរពកាតព្វកិច្ចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកឬព្រៃកោងកាង។

៦- ការបង្កឱ្យភ្លើងឆេះព្រៃលិចទឹកឬព្រៃកោងកាងដោយចេតនា។

៧- ការប្រមូល ការធ្វើសន្និធិ ឬការដឹកជញ្ជូនឈើ អុស ធ្យូង ប្រភេទឈើព្រៃលិចទឹកឬព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ។

៨- ការប្រើឈើព្រៃលិចទឹកឬព្រៃកោងកាងជាវត្ថុធាតុដើម សម្រាប់ផ្តល់ថាមពលក្នុងរោងសិប្បកម្ម រោងចក្រ ឡ ឬមូលដ្ឋានកែច្នៃ។

**មាត្រា២៧ .-**

ការផលិត ការទិញ ឬការលក់ឧបករណ៍នេសាទខ្នាតធំស្របច្បាប់ជាលក្ខណៈពាណិជ្ជកម្មត្រូវមានលិខិតអនុញ្ញាត ពីអង្គភាពជំនាញទទួលបន្ទុកជលផល។

## ជំពូកទី៦
## ការគ្រប់គ្រងនេសាទទឹកសាប

**មាត្រា២៨ .-**

ការធ្វើនេសាទទឹកសាបត្រូវកំណត់ដូចខាងក្រោម៖

១- ការធ្វើនេសាទខ្នាតតូច។

២- ការធ្វើនេសាទខ្នាតមធ្យម។

៣- ការធ្វើនេសាទខ្នាតធំ។



| | | | |
|---|---|---|---|
| ៤៦ | - មងបណ្តែត<br>- មងពាក់ | - ក្រឡា១,៥ស.ម.ឡើង<br>- រដូវបិទនេសាទ ប្រវែងមិនលើស២០០ម. | - ក្នុងកន្លែងការពារសត្វផ្សោត នៅរដូវបើកនេសាទ អនុញ្ញាតឱ្យប្រើក្រឡាតូចជាង៤ស.ម.<br>- ចំពោះតំបន់មេគង្គលើក្នុងខេត្តស្ទឹងត្រែងមិនអនុញ្ញាតឱ្យធ្វើនេសាទក្នុងរដូវបិទនេសាទ |
| ៤៧ | មងក្រឡុកឬមងហ៊ុម | - ក្រឡា១,៥ស.ម.ឡើង<br>- មិនលើស១០០ម. | ប្រើដោយដៃ |
| ៤៨ | មងអូសដៃ | - ក្រឡា១,៥ស.ម.ឡើង<br>- មិនលើស១០០ម. | |
| ៤៩ | អួនអូសដៃ | - ក្រឡា១,៥ស.ម.ឡើង | |

| | | | |
|---|---|---|---|
| ២៨ | តុម | | |
| ២៩ | ប៉ោង | | |
| ៣០ | បុងត្រីឆ្លាំង | | |
| ៣១ | ឡើត្រីកំភ្លាញ | | |
| ៣២ | ទ្រូ | | |
| ៣៣ | សៃយ៉ឺន | ចន្លោះត្រៀមមួយទៅត្រៀមមួយចាប់ពី១,៥ស.ម.ឡើងឬសាច់អួន២,៥ស.ម.ឡើង | |
| ៣៤ | សៃយ៉ឺនកំពឹស | | |
| ៣៥ | លបត្រីកញ្ចុះ | ចន្លោះត្រៀមមួយទៅត្រៀមមួយចាប់ពី១,៥ស.ម.ឡើងឬសាច់អួន២,៥ស.ម.ឡើង | |
| ៣៦ | លប លបណាឬរាំវ ឬលូ ឬឡុក | ចន្លោះត្រៀមមួយទៅត្រៀមមួយចាប់ពី១,៥ស.ម.ឡើងឬសាច់អួន២,៥ស.ម.ឡើង<br>- រួមផ្សំរបាំងព្រួលឬសាច់អួនមិនលើស១៥០ម. ក្នុងរដូវបិទនេសាទនិងមិនលើស២៥០ម.ក្នុងរដូវបើកនេសាទនៅតំបន់បឹងទន្លេសាប<br>- រួមផ្សំរបាំងព្រួលឬសាច់អួនមិនលើស១០០ម. ក្នុងរដូវបិទនេសាទនិងមិនលើស១៥០ម. ក្នុងរដូវបើកនេសាទនៅតំបន់ក្រៅបឹងទន្លេសាប | |
| ៣៧ | ចាន់ | | |
| ៣៨ | សាបឬត្រើង | | |
| ៣៩ | បំពង់ត្រីកញ្ជ្រូក | | |
| ៤០ | លាន់ | | |
| ៤១ | ជូអន្ទង់ | | |
| ៤២ | សំណាញ់ | ក្រឡា១,៥ស.ម.ឡើង | |
| ៤៣ | រំចា៉ | ក្រឡា១,៥ស.ម.ឡើង | មិនប្រើម៉ាស៊ីនឬខ្យល់រួមផ្សំ |
| ៤៤ | ជន | ក្រឡា១,៥ស.ម.ឡើង | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ៤៥ | អញ្ចង | ក្រឡា១,៥ស.ម.ឡើង | ប្រើដោយដៃ |



ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ត្រូវកំណត់តាមប្រភេទឧបករណ៍នេសាទ ដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃច្បាប់នេះ។ ក្នុងករណីចាំបាច់ ប្រភេទឧបករណ៍នេសាទសម្រាប់ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំអាចត្រូវបានកែសម្រួលឬកំណត់បន្ថែមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លក្ខណៈបច្ចេកទេសនៃប្រភេទឧបករណ៍នេសាទ សម្រាប់ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៩ .-**

ការធ្វើនេសាទខ្នាតតូចអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលានិងគ្រប់ទីកន្លែងក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប លើកលែងតែកន្លែងអភិរក្សជលផលនិងកន្លែងសហគមន៍នេសាទដែលអនុញ្ញាតចំពោះតែសមាជិកសហគមន៍។

ការធ្វើនេសាទខ្នាតមធ្យមក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប អាចប្រព្រឹត្តទៅបានក្នុងកន្លែងនេសាទសាធារណៈនៅរដូវបើកនេសាទតែប៉ុណ្ណោះ។

ចំពោះការធ្វើនេសាទខ្នាតតូចឬខ្នាតមធ្យមក្នុងកន្លែងសហគមន៍នេសាទ អាចប្រព្រឹត្តទៅបានសម្រាប់តែសមាជិកសហគមន៍នេសាទស្របតាមលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់កន្លែងសហគមន៍នេសាទនីមួយៗដែលកំណត់ដោយអង្គភាពជំនាញទទួលបន្ទុកជលផល។

ការធ្វើនេសាទខ្នាតធំនៅក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប អាចប្រព្រឹត្តទៅបានក្នុងកន្លែងនេសាទដែលបានកំណត់ តាមពេលវេលាជាក់លាក់ស្របតាមនីតិវិធីនិងបទប្បញ្ញត្តិនៃច្បាប់នេះ។

ការនេសាទសម្រាប់ការសិក្សាពិសោធស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល អាចប្រព្រឹត្តទៅបានគ្រប់ទីកន្លែងនៃតំបន់គ្រប់គ្រងជលផលទឹកសាប លុះត្រាមានការអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល។

**មាត្រា៣០ .-**

បុគ្គលដែលធ្វើការនេសាទខ្នាតមធ្យមឬខ្នាតធំ ក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដែលអនុញ្ញាតឱ្យធ្វើការនេសាទ ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទ មានកាតព្វកិច្ចបង់ពន្ធថ្លៃឈ្នួលនេសាទជូនរដ្ឋ និងគោរពតាមលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតឱ្យធ្វើការនេសាទ។ ចំពោះការធ្វើនេសាទខ្នាតតូចមិនតម្រូវឱ្យមានលិខិតអនុញ្ញាត។

បែបបទនិងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទខ្នាតមធ្យមនិងខ្នាតធំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការប្រគល់ដាយត្រីឬដាយបង្កងឱ្យធ្វើនេសាទ អាចប្រព្រឹត្តទៅបានតាមការវិនិយោគ តាមការដេញថ្លៃជាសាធារណៈឬជួលតាមការព្រមព្រៀងចំពោះដាយត្រីឬដាយបង្កងដែលគ្មានអ្នកដេញថ្លៃ។

នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

បុគ្គលដែលធ្វើការនេសាទដាយត្រីឬដាយបង្កង ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនេសាទ សៀវភៅបន្ទុក និងសៀវភៅកត់ត្រាស្ថិតិផលនេសាទ។ រាល់ការធ្វើនេសាទដាយត្រីឬដាយបង្កង ត្រូវកត់ត្រាស្ថិតិផលនេសាទនៅក្នុងសៀវភៅស្ថិតិផលនេសាទនិងគោរពតាមលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតនិងសៀវភៅបន្ទុក។

គំរូសៀវភៅបន្ទុកដាយត្រីឬដាយបង្កង ត្រូវរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣២ .-**

ហាមឃាត់សកម្មភាពដូចខាងក្រោមក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបៈ

១- ការធ្វើនេសាទខ្នាតមធ្យមឬខ្នាតធំក្នុងរដូវបិទនេសាទ។

២- ការធ្វើនេសាទខ្នាតធំក្នុងកន្លែងនេសាទសាធារណៈ។

៣- ការធ្វើនេសាទដាយត្រីឬដាយបង្កងខុសទីតាំងដែលបានកំណត់។

៤- ការធ្វើនេសាទឬការប្រើឧបករណ៍នេសាទដែលរាំងស្ទះផ្លូវនាវាចរណ៍ឬការធ្វើនេសាទរួមផ្សំរបាំងព្រួលឬរបាំងសាច់អួនលាតសន្ធឹងលើសពី២/៣(ពីរភាគបី)នៃទទឹងមុខទឹកអូរ ព្រែក ឬស្ទឹង។

៥- ការធ្វើនេសាទដោយមងបោះ មងកាំង ឬមងពស់ថ្លាន់ ឬមង៣(បី)ជាន់គ្រប់ប្រភេទ។

៦- ការធ្វើនេសាទដោយមងដែលមានក្រឡាធំជាង១៥(ដប់ប្រាំ)សង់ទីម៉ែត្រ។

៧- ការធ្វើនេសាទដោយប្រើខ្សែចងគ្រប់ប្រភេទឱ្យមានរំញ័រ ឬមធ្យោបាយផ្សេងទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។

៨- ការធ្វើនេសាទដោយឧបករណ៍អួនឬការធ្វើនេសាទរួមផ្សំរបាំងព្រួលឬរបាំងសាច់អួនខុសទីតាំង ប្រវែង ទំហំ ក្រឡា ឬពេលវេលាដែលបានកំណត់។

៩- ការធ្វើនេសាទដោយអួនអូសឬឈិបយន្តនៅទឹកសាប។

១០- ការដាក់សម្រាស់ឬការធ្វើនេសាទដោយប្រើភ្លើងរួមផ្សំឬមធ្យោបាយផ្សេងទៀត សម្រាប់ទាក់ទាញត្រី ឬវារីសត្វផ្សេងទៀត។

១១- ការធ្វើនេសាទដោយបូម បាច ពង្រីងផ្ទៃកណាមួយនៃតំបន់គ្រប់គ្រងជលផលដែលអាចបង្កឬធ្វើឱ្យមហន្តរាយដល់ធនធានជលផលដែលជាប្រយោជន៍សាធារណៈ។

១២- ការធ្វើនេសាទដោយទំនប់រួមផ្សំនឹងឧបករណ៍នេសាទដែលធ្វើឱ្យប៉ះពាល់ដល់ធនធានជលផល។

១៣- ការធ្វើនេសាទដែលនាំឱ្យរាំងស្ទះចរាចរណ៍ត្រីនៅតំបន់បឹងទន្លេសាប។

**មាត្រា៣៣ .-**

ការធ្វើនេសាទដោយឧបករណ៍អួនឬការធ្វើនេសាទរួមផ្សំរបាំងព្រួលឬរបាំងសាច់អួន នៅក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប អាចអនុញ្ញាតឱ្យធ្វើបានតាមប្រវែង ទំហំ ក្រឡានៃឧបករណ៍នេសាទ ពេលវេលា និងទីតាំងដែលអនុញ្ញាតឱ្យធ្វើការនេសាទ។ ប្រវែង ទំហំ ក្រឡានៃឧបករណ៍នេសាទ ពេលវេលា និងទីតាំងដែលអនុញ្ញាតឱ្យធ្វើការនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការធ្វើនេសាទដោយឧបករណ៍ម៉ាញ់ នាម ជន មងក្រឡុក មងអូស អួន ឈ្នាងអូសលៀសឬខ្ចៅនៅទឹកសាបដែលអូសឬរុញដោយប្រើកម្លាំងម៉ាស៊ីន អាចអនុញ្ញាតឱ្យធ្វើតាមកម្លាំងម៉ាស៊ីន ពេលវេលា និងទីតាំងដែលអនុញ្ញាតឱ្យធ្វើនេសាទ។ កម្លាំងម៉ាស៊ីន ពេលវេលា និងទីតាំងដែលអនុញ្ញាតឱ្យធ្វើការនេសាទត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



**ឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល**
**ប្រភេទឧបករណ៍នេសាទ នាវានេសាទ និងនាវាពាក់ព័ន្ធនឹងការនេសាទ**

**១- ប្រភេទឧបករណ៍នេសាទ**

**ក- ឧបករណ៍នេសាទទឹកសាប**

**ក១- ឧបករណ៍នេសាទទឹកសាបខ្នាតតូច**

| ល.រ. | ឈ្មោះឧបករណ៍នេសាទ | ទំហំ/ប្រវែង/ក្រឡា | ផ្សេងៗ |
|---|---|---|---|
| ១ | សន្ទូចផ្លែមួយ | | |
| ២ | សន្ទូចបោះ | | |
| ៣ | សន្ទូចរនង | | មិនអនុញ្ញាតក្នុងកន្លែងការពារសត្វផ្សោត |
| ៤ | សន្ទូចបបក់ | | |
| ៥ | សន្ទូចបង្កៃ | | |
| ៦ | កង្វារក្តាមឬកង្កែប | | |
| ៧ | កង្វារត្រីឆ្លូញ | | ប្រើដោយដៃ |
| ៨ | ចង្រប់ | | |
| ៩ | ច្បូក | | មិនប្រើកៃវឆ្លុះរួមផ្សំ |
| ១០ | សាង | | |
| ១១ | ស្ន | | |
| ១២ | សម | | |
| ១៣ | ព្រួញបាញ់ | | មិនអនុញ្ញាតក្នុងអន្លង់ |
| ១៤ | ដៃកាប់ត្រី | | |
| ១៥ | អង្រុត | | |
| ១៦ | កន្ស៊ំ | | |
| ១៧ | ឈ្នាងជញ្ជាត់ | | |
| ១៨ | ឈ្នាងត្រាំ | | ប្រើដោយដៃ |
| ១៩ | ឈ្នាងអូសឬរុញ ខ្ចៅឬលៀស | ក្រឡា២,៥ស.ម.ឡើង | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ២០ | ឈ្នាងកង | | ប្រើដោយដៃ |
| ២១ | កញ្ជ្រោងជងត្រី | | ប្រើដោយដៃ |
| ២២ | ផ្ទង | | ប្រើដោយដៃ |
| ២៣ | ប្រូម | | ប្រើដោយដៃ |
| ២៤ | ឈ្នក់ឬឆ្នុក | ក្រឡា១,៥ស.ម.ឡើង | មិនប្រើភ្លើងរួមផ្សំ |
| ២៥ | ជីត | | |
| ២៦ | ដុប | | |
| ២៧ | ឈាយ | | |

**ស្តង់ដាអនាម័យ** សំដៅដល់លក្ខខណ្ឌឬកម្រិតចាំបាច់ដើម្បីធានានូវអនាម័យគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផលិតកម្មក្នុងការធ្វើអាជីវកម្មឬពាណិជ្ជកម្ម ដើម្បីធានាសុវត្ថិភាពម្ហូបអាហារ។

**អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់** សំដៅដល់អង្គការដែលទទួលខុសត្រូវក្នុងការរៀបចំបទប្បញ្ញត្តិ និងចាត់វិធានការគ្រប់គ្រងនិងអភិរក្សធនធានជលផលនៅក្នុងសមុទ្រអន្តរជាតិ។

**អាជីវកម្មផល ផលិតផលជលផល** សំដៅដល់ការទិញ ការលក់ ការចែកចាយ ការធ្វើសន្និធិ ឬការកែច្នៃផលផលិតផលជលផល។

**អ្នកអង្កេតការណ៍នាវានេសាទ** សំដៅដល់បុគ្គលដែលត្រូវបានចាត់តាំងដោយអង្គភាពជំនាញទទួលបន្ទុកជលផល ដើម្បីតាមដានការធ្វើនេសាទនិងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

**ឧបករណ៍តាមដាននាវា** សំដៅដល់ឧបករណ៍ដែលបំពាក់លើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទសម្រាប់តាមដានសកម្មភាពនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ។

**ឱសថវារីវប្បកម្ម** សំដៅដល់សារធាតុមួយមុខឬបន្សំសារធាតុច្រើនមុខដែលមានប្រភពពីសារធាតុគីមីជីវផលិតផលឬអតិសុខុមប្រាណសម្រាប់ព្យាបាលវារីសត្វ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



**មាត្រា៣៤ .-**

រដូវបិទនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប ត្រូវកំណត់ដូចខាងក្រោម៖

១- ចាប់ពីថ្ងៃទី១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែកញ្ញា ចំពោះតំបន់គ្រប់គ្រងជលផលទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ។

២- ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែតុលា ចំពោះតំបន់គ្រប់គ្រងជលផលទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ។

រដូវបិទនេសាទតាមតំបន់ផ្សេងទៀតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រជាក់លាក់។

## ជំពូកទី៧
## ការគ្រប់គ្រងនេសាទសមុទ្រ
### ផ្នែកទី១
### ការគ្រប់គ្រងការធ្វើនេសាទ នាវានេសាទ និងនាវាពាក់ព័ន្ធនឹងការនេសាទ

**មាត្រា៣៥ .-**

ការធ្វើនេសាទសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

១- ការធ្វើនេសាទខ្នាតតូច។

២- ការធ្វើនេសាទខ្នាតមធ្យម។

៣- ការធ្វើនេសាទខ្នាតធំ។

ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ត្រូវកំណត់តាមប្រភេទឧបករណ៍នេសាទឬនាវានេសាទដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃច្បាប់នេះ។ ក្នុងករណីចាំបាច់ ប្រភេទឧបករណ៍នេសាទ សម្រាប់ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ អាចត្រូវបានកែសម្រួលឬកំណត់បន្ថែម ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លក្ខណៈបច្ចេកទេសនៃប្រភេទឧបករណ៍នេសាទ សម្រាប់ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣៦ .-**

បុគ្គលដែលធ្វើការនេសាទខ្នាតមធ្យមឬខ្នាតធំ ឬប្រើនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំ ក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ ត្រូវមានលិខិតអនុញ្ញាត មានកាតព្វកិច្ចបង់ពន្ធថ្លៃឈ្នួលនេសាទជូនរដ្ឋ និងគោរពតាមលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតឱ្យធ្វើការនេសាទ។ ចំពោះការធ្វើនេសាទខ្នាតតូចមិនតម្រូវឱ្យមានលិខិតអនុញ្ញាត។

បែបបទនិងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទខ្នាតមធ្យមនិងខ្នាតធំនិងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣៧ .-**

ការធ្វើនេសាទខ្នាតតូចអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលានិងគ្រប់ទីកន្លែងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ លើកលែងតែកន្លែងអភិរក្សជលផលនិងកន្លែងសហគមន៍នេសាទដែលអនុញ្ញាតចំពោះតែសមាជិកសហគមន៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការធ្វើនេសាទខ្នាតមធ្យមអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាក្នុងកន្លែងនេសាទសាធារណៈនៃតំបន់គ្រប់គ្រងជលផលសមុទ្រ លើកលែងអួនអូស ឈិបយន្ត និងឈ្នាងអូសគ្រែង គ្រំ ឬលៀស អាចប្រព្រឹត្តទៅបានក្នុងកន្លែងនេសាទតាមឆ្នេរចំពោះតែទីតាំងដែលបានកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការធ្វើនេសាទខ្នាតតូចឬខ្នាតមធ្យម ក្នុងកន្លែងសហគមន៍នេសាទ អាចប្រព្រឹត្តទៅបានសម្រាប់តែសមាជិកសហគមន៍នេសាទ ស្របតាមលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់កន្លែងសហគមន៍នេសាទនីមួយៗដែលកំណត់ដោយអង្គភាពជំនាញទទួលបន្ទុកជលផល។

ការធ្វើនេសាទខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ អាចប្រព្រឹត្តទៅបានតែក្នុងកន្លែងនេសាទសមុទ្រក្រៅ។

ការនេសាទសម្រាប់ការសិក្សាពិសោធស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល អាចប្រព្រឹត្តទៅបានគ្រប់ទីកន្លែងនៃតំបន់គ្រប់គ្រងជលផលសមុទ្រ លុះត្រាមានការអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល។

**មាត្រា៣៨ .-**

បុគ្គលដែលធ្វើការនេសាទដោយប្រើឧបករណ៍នេសាទលាតសន្ទឹងកាត់ព្រែកឬស្ទឹងនៃកន្លែងនេសាទតាមឆ្នេរ ត្រូវបើកមុខទឹកយ៉ាងតិច១/២(មួយភាគពីរ)នៃប្រវែងទទឹងព្រែកឬស្ទឹងនៅពេលទឹកនាច ដើម្បីឱ្យជលយានធ្វើចរាចរណ៍និងត្រូវរុះរើឧបករណ៍នេសាទចេញឱ្យអស់មុនថ្ងៃផុតកំណត់នៃលិខិតអនុញ្ញាត។

**មាត្រា៣៩ .-**

ហាមឃាត់សកម្មភាពដូចខាងក្រោមក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ៖

១- ការធ្វើនេសាទឬប្រើឧបករណ៍នេសាទដែលរាំងស្ទះផ្លូវនាវាចរណ៍។

២- ការធ្វើនេសាទឬធ្វើសកម្មភាពផ្សេងទៀតក្នុងតំបន់ស្មៅសមុទ្រឬផ្កាថ្ម ដែលប៉ះពាល់ដល់ការលូតលាស់នៃស្មៅសមុទ្រឬផ្កាថ្ម។

៣- ការចូលសំចតនាវាដោយបោះយុថ្កាក្នុងតំបន់ផ្កាថ្ម។

៤- ការបំផ្លាញស្មៅសមុទ្រឬផ្កាថ្មដោយសកម្មភាពផ្សេងទៀត។

៥- ការធ្វើនេសាទដោយមងឬអួនដែលមានក្រឡាតូចជាង១,៥(មួយក្បៀសប្រាំ)សង់ទីម៉ែត្រ លើកលែងតែអួនកាកឹម។

៦- ការធ្វើនេសាទដោយឧបករណ៍អួនអូស ឈិបយន្ត ឬឈ្នាងអូសគ្រែង គ្រំ ឬលៀស នៅកន្លែងនេសាទតាមឆ្នេរក្រៅទីតាំងដែលបានកំណត់។

៧- នាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ ធ្វើសកម្មភាពខុសពីកន្លែងនេសាទដែលបានកំណត់។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុញ្ញាតឱ្យធ្វើសកម្មភាពដែលមានកំណត់ក្នុងចំណុចទី៣នៃកថាខណ្ឌទី១ខាងលើ។

**មាត្រា៤០ .-**

ផែននៃការគ្រប់គ្រងនិងអភិរក្សជលផលសមុទ្រ ត្រូវកំណត់ដោយអនុក្រឹត្យ។



**ផលិតផលជលផល** សំដៅដល់ផលដែលបានកែច្នៃពីផលជលផល។

**ព្រៃកោងកាង** សំដៅដល់រុក្ខជាតិគ្រប់ប្រភេទដែលដុះក្នុងតំបន់ដែលទទួលរបបទឹកជោរនាចនៃសមុទ្រ ជាអាទិ៍ដើមកោងកាង បាសាក់ ក្រញិប ស្មែ ឈើជ័រ អំពូល អំពាល ប្រង់ ចាក។

**ព្រៃលិចទឹក** សំដៅដល់រុក្ខជាតិគ្រប់ប្រភេទដុះក្នុងតំបន់ដែលលិចទឹកតាមរដូវកាល ជាអាទិ៍ដើមរាំង សណ្តាន់ រំដេញ ត្រស់ តាអូវ ផ្ទោល ថ្លើមអណ្តើក អញ្ចាញ ត្រែង ស្នោ កក់ ស្មៅលិចទឹក។

**រដូវបិទនេសាទ** សំដៅដល់ពេលវេលាដែលបានកំណត់ជាក់លាក់នៃការហាមឃាត់ក្នុងការធ្វើនេសាទ។

**រោគសាស្ត្រ** សំដៅដល់ការសិក្សាតាមបែបវិទ្យាសាស្ត្រអំពីហេតុបង្កនិងឥទ្ធិពលនៃជំងឺ ដោយផ្តោតលើការសិក្សាអំពីរោគសញ្ញា ការចម្លងជំងឺ ការរីករាលដាលនៃជំងឺ ការគ្រប់គ្រង និងការព្យាបាលជំងឺ។

**វារិជាត** សំដៅដល់វារីសត្វឬវារីរុក្ខជាតិ។

**វារីវប្បកម្ម** សំដៅដល់សកម្មភាព បង្កាត់ ភ្ញាស់ ចិញ្ចឹម បំប៉នវារីសត្វ ឬដាំ បណ្តុះ បង្កាត់វារីរុក្ខជាតិ។

**វារីសត្វ** សំដៅដល់សត្វមានឬគ្មានឆ្អឹងកងខ្នងដែលរស់នៅក្នុងទឹកជាអចិន្ត្រៃយ៍ឬក្នុងទឹកផងនិងលើគោកផង ជាអាទិ៍ត្រី បង្កង បង្គា ក្តាម ខ្យង លៀស គ្រែង គ្រំ កង្កែប អណ្តើក ពស់ព្រលឹត ក្រពើ ផ្សោត។

**វារីរុក្ខជាតិ** សំដៅដល់រុក្ខជាតិទឹកដែលដុះនិងរីកលូតលាស់នៅក្នុងទឹក ជាអាទិ៍កក់ ព្រលឹត រំចង់ កំប្លោក ត្រកួន កំពឹងពួយ យាប្លង ក្រចាប់ សារាយ ចក ប្លង់តុងរុក្ខជាតិ។

**សកម្មភាពពាក់ព័ន្ធនឹងការនេសាទ** សំដៅដល់ប្រតិបត្តិការណាមួយក្នុងការគាំទ្រឬការរៀបចំសម្រាប់ការនេសាទ រួមមាន ការឡើង ការផ្ទេរ ការដឹកជញ្ជូន ការវេចខ្ចប់ ការកែច្នៃផល ផលិតផលជលផល ដែលពីមុនមិនធ្លាប់បានចូលចតនៅកំពង់ផែណាមួយ ក៏ដូចជាការផ្តល់បុគ្គលិក ប្រេងឥន្ធនៈ ឧបករណ៍នេសាទ និងការផ្គត់ផ្គង់ផ្សេងៗទៀតនៅក្នុងសមុទ្រ។

**សហគមន៍នេសាទ** សំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលបានព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តចូលរួមគ្រប់គ្រង ថែរក្សា ការពារ អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពនៅក្នុងតំបន់គ្រប់គ្រងជលផល ស្របតាមបទដ្ឋានគតិយុត្ត។

**សាយតេស** សំដៅដល់អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

**សៀវភៅបន្ទុកជាយត្រីឬជាយបង្កង** សំដៅដល់សៀវភៅសម្រាប់កំណត់លក្ខខណ្ឌនៃការធ្វើនេសាទជាយត្រី ឬជាយបង្កង ជាអាទិ៍ប្រភេទឧបករណ៍នេសាទ កាលបរិច្ឆេទនៃការធ្វើអាជីវកម្ម ការបង់ថ្លៃឈ្នួលនេសាទ និងការរុះរើឧបករណ៍នេសាទនិងកាតព្វកិច្ចផ្សេងទៀតរបស់អ្នកទទួលសិទ្ធិធ្វើអាជីវកម្ម។

**សៀវភៅសកម្មភាពពាក់ព័ន្ធនឹងការនេសាទ** សំដៅដល់សៀវភៅដែលចេញដោយអង្គភាពជំនាញទទួលបន្ទុកជលផល សម្រាប់កត់ត្រាព័ត៌មានអំពីសកម្មភាពនៃការវេចខ្ចប់ កែច្នៃ ផ្ទេរ ឬការដឹកជញ្ជូនផល ផលិតផលជលផល រួមទាំងការផ្តល់សេវាកម្មនាវិក ប្រេងឥន្ធនៈ និងការផ្គត់ផ្គង់ផ្សេងទៀត។

**សៀវភៅស្ថិតិផលនេសាទ** សំដៅដល់សៀវភៅដែលចេញដោយអង្គភាពជំនាញទទួលបន្ទុកជលផល សម្រាប់កត់ត្រាស្ថិតិផលនេសាទ ព័ត៌មាន និងទិន្នន័យនៃការនេសាទ។

**ទីជម្រក** សំដៅដល់ទីកន្លែងសម្រាប់ជ្រកកោនរបស់វារីសត្វក្នុងតំបន់គ្រប់គ្រងជលផល មានជាអាទិ៍តំបន់ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម ស្មៅសមុទ្រ អន្លង់ជ្រៅៗ បឹង អាងទឹក និងកន្លែងអភិរក្ស។

**ទំនាបលិចទឹក** សំដៅដល់ដីទំនាបលិចទឹកដែលទទួលរបបទឹកតាមរដូវកាល រួមមាន វាលទំនាប វាលស្មៅ។

**ធនធានជលផល** សំដៅដល់សរីរាង្គទឹកសាបនិងសមុទ្រ ជាសត្វនិងរុក្ខជាតិ មានជីវិតឬគ្មានជីវិត ជាអាទិ៍មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀត ដែលបង្កកំណើតក្នុងទឹក វារីរុក្ខជាតិ ផ្កាថ្ម ព្រៃលិចទឹក និងព្រៃកោងកាងជាដើម។

**នាទីព្រៃកោងកាង** សំដៅដល់ដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រ គ្របដណ្តប់ដោយព្រៃកោងកាង និងតំបន់លិចទឹកដែលត្រូវការពារ។

**នាទីព្រៃលិចទឹក** សំដៅដល់ដីសាធារណៈរបស់រដ្ឋដែលលិចទឹកនារដូវជំនោរឡើង គ្របដណ្តប់ដោយព្រៃលិចទឹកនិងតំបន់លិចទឹកដែលត្រូវការពារ។

**នាវានេសាទ** សំដៅដល់នាវាដែលមានបំពាក់ឧបករណ៍សម្ភារៈនេសាទសម្រាប់ធ្វើនេសាទ។

**នាវានេសាទសញ្ជាតិខ្មែរ** សំដៅដល់នាវានេសាទសមុទ្រ ដែលបានចុះបញ្ជីជានាវាសញ្ជាតិខ្មែរតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**នាវានេសាទបរទេស** សំដៅដល់នាវានេសាទសមុទ្រដែលចុះបញ្ជីជានាវានេសាទសមុទ្រដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស ដើម្បីទទួលភាពស្របច្បាប់សម្រាប់ធ្វើនេសាទ។

**នាវាពាក់ព័ន្ធនឹងការនេសាទ** សំដៅដល់នាវាដែលប្រើសម្រាប់គាំទ្រដល់សកម្មភាពនេសាទ ជាអាទិ៍នាវាដឹកជញ្ជូន ផ្ទេរ កែច្នៃ វេចខ្ចប់ផល ផលិតផលជលផល ឬនាវាដឹកជញ្ជូនប្រេងឥន្ធនៈ ឧបករណ៍នេសាទ និងការផ្តល់សេវាផ្សេងទៀតគាំទ្រដល់នាវានេសាទ។

**បញ្ជីនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ**(IUU vessel List) សំដៅដល់បញ្ជីឈ្មោះនាវានេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិដែលកំណត់ដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ដោយបង្ហាញពីអត្តសញ្ញាណនាវា ដូចជា ឈ្មោះ ទង់ជាតិ ហេស្សនាម។

**ប្រតិបត្តិករ** សំដៅដល់បុគ្គលដែលទទួលខុសត្រូវប្រតិបត្តិការដឹកនាំឬគ្រប់គ្រងនាវា រួមមានម្ចាស់ អ្នកជួលនាយនាវា និងអ្នកទទួលប្រយោជន៍។

**ប្រតិវេទន៍នៃផល ផលិតផលជលផល** សំដៅដល់លិខិតសម្រាប់ប្រកាសអំពីផល ផលិតផលជលផលក្នុងការឡើងឬផ្ទេរផល ផលិតផលជលផល។

**ប្រព័ន្ធតាមដាននាវា** សំដៅដល់ឧបករណ៍សម្រាប់តាមដានសកម្មភាពនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ។

**ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់** សំដៅដល់ប្រភេទវារីសត្វនិងវារីរុក្ខជាតិដែលផលស្តុកថយចុះក្នុងធម្មជាតិ ជាអាទិ៍ត្រីរាជ ត្រីគល់រាំង សត្វផ្សោត អណ្តើកហ្លួង ជ្រូកទឹក។

**ផលជលផល** សំដៅដល់ផលនេសាទឬធនធានជលផលដែលប្រមូលពីធម្មជាតិឬវារីវប្បកម្ម រួមមានវារីសត្វនិងវារីរុក្ខជាតិ។



**មាត្រា៤១ .-**

នាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ ត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

១- នាវាខ្នាតតូច។

២- នាវាខ្នាតមធ្យម។

៣- នាវាខ្នាតធំ។

ប្រភេទនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ ដូចមានក្នុងឧបសម្ព័ន្ធទី២នៃច្បាប់នេះ។ ក្នុងករណីចាំបាច់ ប្រភេទនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទអាចត្រូវបានកែសម្រួលដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤២ .-**

ការនាំចូលនាវាខ្នាតធំសម្រាប់ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ត្រូវមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

ការនាំចូលនាវាខ្នាតមធ្យមសម្រាប់ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នីតិវិធីនៃការស្នើសុំនាំចូលនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤៣ .-**

នាវាខ្នាតមធ្យមឬខ្នាតធំ មុនផ្តល់លិខិតអនុញ្ញាតឱ្យធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាឬតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវមានការត្រួតពិនិត្យនិងវាយតម្លៃលក្ខណៈបច្ចេកទេសនៃឧបករណ៍នេសាទនិងសម្ភារៈរួមផ្សំសម្រាប់ធ្វើនេសាទពីអង្គភាពជំនាញទទួលបន្ទុកជលផល។

នីតិវិធីសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃលក្ខណៈបច្ចេកទេសនៃឧបករណ៍នេសាទនិងសម្ភារៈរួមផ្សំសម្រាប់ធ្វើនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤៤ .-**

បុគ្គលដែលធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតមធ្យមឬខ្នាតធំ ត្រូវ៖

១- មានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល បន្ទាប់ពីទទួលបានការណែនាំនិងបណ្តុះបណ្តាលពាក់ព័ន្ធនឹងបទប្បញ្ញត្តិអន្តរជាតិនានាដែលបុគ្គលធ្វើនេសាទត្រូវអនុវត្ត។

២- អនុវត្តតាមវិធានការគ្រប់គ្រងនិងអភិរក្សនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធដែលនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ ធ្វើសកម្មភាព។

៣- អនុវត្តតាមស្តង់ដាអន្តរជាតិទាក់ទងនឹងលក្ខខណ្ឌការងារ ការរស់នៅ និងសុវត្ថិភាពលើផ្ទៃសមុទ្រលើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ និងធានាថាកម្មករនៅលើនាវាឬនាវាពាក់ព័ន្ធនឹងការនេសាទមិនមានការប្រើពលករដោយការបង្ខិតបង្ខំ ការជួញដូរមនុស្ស ឬការប្រើពលករជាទាសករ។

៤- អនុវត្តតាមលក្ខខណ្ឌតម្រូវនៃការដាក់ស្លាកសញ្ញាសម្គាល់នាវា និងកំណត់អត្តសញ្ញាណនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ។

៥- អនុវត្តតាមលក្ខខណ្ឌតម្រូវនៃការធ្វើរបាយការណ៍អំពីផលនេសាទ ឧបករណ៍នេសាទ ទីតាំងនាវា តំបន់ធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

៦- អនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការបំពាក់និងដំណើរការឧបករណ៍តាមដាននាវាឬនាវាពាក់ព័ន្ធនឹងការនេសាទ។

៧- អនុវត្តតាមលក្ខខណ្ឌតម្រូវនៃការប្រើកំពង់ផែនេសាទ រួមទាំងការឡើងនិងផ្ទេរផល ផលិតផលជលផល។

៨- រាយការណ៍អំពីទីតាំងប្រតិបត្តិការនៃការធ្វើនេសាទ ទិញ និងលក់ផលនេសាទ ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងទៀត។

៩- រក្សាទុកលិខិតអនុញ្ញាតច្បាប់ដើមឬច្បាប់ថតចម្លងផ្លូវការនៅក្នុងនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទគ្រប់ពេលក្នុងអំឡុងពេលលិខិតអនុញ្ញាតនៅមានសុពលភាពនិងនាយនាវា ត្រូវបង្ហាញដល់មន្ត្រីជលផលមានសមត្ថកិច្ចតាមការស្នើសុំ។

**មាត្រា៤៥ .-**

អង្គភាពជំនាញទទួលបន្ទុកជលផលមិនត្រូវអនុញ្ញាតឱ្យធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាឬតំបន់ក្រៅដែនយុត្តាធិការជាតិ ក្នុងករណីណាមួយដូចខាងក្រោម៖

១- នាវាមិនបានចុះបញ្ជីត្រឹមត្រូវឬចុះបញ្ជីច្រើនប្រទេស។

២- បុគ្គលឬនាវាត្រូវបានសង្ស័យធ្វើការនេសាទឬធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ឬមានក្នុងបញ្ជីនាវាខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៣- នាវាមិនអនុលោមតាមស្តង់ដាអន្តរជាតិទាក់ទងនឹងលក្ខខណ្ឌការងារ ស្ថានភាពរស់នៅ ឬសុវត្ថិភាពលើផ្ទៃសមុទ្រ។

៤- បុគ្គលឬនាវាបរទេសដែលត្រូវបានផ្តន្ទាទោសតាមច្បាប់នៃរដ្ឋម្ចាស់ទង់ជាតិ ដោយបានព្យួរឬដកហូតលិខិតអនុញ្ញាត។

៥- បុគ្គលស្នើសុំមានទំនាក់ទំនងដោយផ្ទាល់ជាមួយបុគ្គលឬនាវាដែលបានប្រព្រឹត្តបទល្មើសជលផលឬមិនគោរពតាមសេចក្តីសម្រេចពិន័យអន្តការណ៍ឬសេចក្តីសម្រេចរបស់តុលាការ។

**មាត្រា៤៦ .-**

ក្នុងករណីមានកិច្ចព្រមព្រៀងឬសន្ធិសញ្ញាអន្តរជាតិ ស្តីពីការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទដែលព្រះរាជាណាចក្រកម្ពុជាជាភាគី នាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទអាចធ្វើសកម្មភាពបាននៅកន្លែងនេសាទដែលបានកំណត់។

**មាត្រា៤៧ .-**

នាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទដែលមានលិខិតអនុញ្ញាតឱ្យធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ អាចចូលចតកំពង់ផែនេសាទដែលបានកំណត់ត្រូវជូនដំណឹងមុន២៤(ម្ភៃបួន)ម៉ោង មកអង្គភាពជំនាញទទួលបន្ទុកជលផល។

នាវាដែលបានអនុញ្ញាតឱ្យចូលចត មុននឹងចាកចេញ ត្រូវជូនដំណឹងមុន១២(ដប់ពីរ)ម៉ោង មកអង្គភាពជំនាញទទួលបន្ទុកជលផល។



**ការផ្ទេរផល ផលិតផលជលផល** សំដៅដល់ការផ្ទេរផល ផលិតផលជលផលពីនាវាមួយទៅនាវាមួយដោយផ្ទាល់ក្នុងតំបន់គ្រប់គ្រងជលផល ឬនៅកំពង់ផែ ឬកន្លែងឡើងផល ផលិតផលជលផល។

**ការឡើងផល ផលិតផលជលផល** សំដៅដល់ការនាំយកផល ផលិតផលជលផលចូលឬលើកដាក់នៅផែឬកន្លែងឡើងផល ផលិតផលជលផល។

**ការអនុវត្តវារីវប្បកម្មល្អ** សំដៅដល់ការអនុវត្តលើការធ្វើវារីវប្បកម្មវារិជាត ដែលអនុវត្តតាមគោលការណ៍សុវត្ថិភាពម្ហូបអាហារ សុខភាពនិងសុខុមាលភាពសត្វ និងបរិស្ថានល្អ។

**ការអនុវត្តអនាម័យល្អ** សំដៅដល់លក្ខខណ្ឌអនាម័យនិងវិធានការចាំបាច់នានា ដើម្បីធានាសុវត្ថិភាពម្ហូបអាហារគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ម្ហូបអាហារ រួមមានការផលិត ការវេចខ្ចប់ ការលើកដាក់ ការថែរក្សា និងការដឹកជញ្ជូនផល ផលិតផលជលផល។

**ការពិន័យអន្តរការណ៍** សំដៅដល់ការពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចជលផលដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌។

**ការពិន័យជាប្រាក់** សំដៅដល់ការពិន័យជាប្រាក់ដោយស្ថាប័នតុលាការ។

**កំពង់ផែនេសាទ** សំដៅដល់កំពង់ផែដែលមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់នាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទចូលចត ដើម្បីឡើងឬផ្ទេរផល ផលិតផលជលផល ឬប្រើសេវាកម្មផ្សេងៗ ជាអាទិ៍ការផ្គត់ផ្គង់ឧបករណ៍នេសាទ ប្រេងឥន្ធនៈ ទឹកកក។

**ការនាំឆ្លងកាត់ផល ផលិតផលជលផល** សំដៅដល់ការដឹកជញ្ជូនផល ផលិតផលជលផលឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា។

**ជលផល** សំដៅដល់ការការពារ ការអភិរក្ស និងការអភិវឌ្ឍវារិជាត ការធ្វើនេសាទ សកម្មភាពពាក់ព័ន្ធនឹងការនេសាទ ការប្រមូលវារិជាត ការធ្វើវារីវប្បកម្ម ការកែច្នៃ និងការធ្វើអាជីវកម្ម ការនាំចេញ នាំចូលនូវផល ផលិតផលជលផល។

**ដាយត្រី** សំដៅដល់ឧបករណ៍នេសាទ រួមផ្សំដោយក្បូនឬទូកភ្ជាប់ទៅនឹងយុថ្កាបោះសម្រាប់បើកមាត់ដាយដែលមានក្រឡាប្រដេញពីធំទៅតូចរហូតដល់ថ្នក់កន្ទុយដាយ ប្រើសម្រាប់ចាប់ត្រីចម្រុះដែលបម្លាស់ទីពីតំបន់បឹងទន្លេសាបនិងទន្លេសាប។

**តំបន់ក្រៅដែនយុត្តាធិការជាតិ** សំដៅដល់តំបន់សមុទ្រដែលស្ថិតក្រៅតំបន់សេដ្ឋកិច្ចផ្តាច់មុខ រួមមានសមុទ្រអន្តរជាតិនិងតំបន់សមុទ្រនៃរដ្ឋដទៃ។

**តំបន់សេដ្ឋកិច្ចផ្តាច់មុខ** សំដៅដល់សមុទ្រដែលស្ថិតក្នុងដែនយុត្តាធិការ លាតសន្ធឹងចាប់ពីខ្សែបន្ទាត់មូលដ្ឋានរហូតដល់សមុទ្រខាងក្រៅចម្ងាយ២០០(ពីររយ)ម៉ាយ៍សមុទ្រ(Nautical Mile)ឬ៣៧០,៤(បីរយចិតសិបក្បៀសបួន)គីឡូម៉ែត្រ។

**តំបន់ទេសចរណ៍ជលផល** សំដៅដល់ផ្នែកមួយនៃតំបន់គ្រប់គ្រងជលផលដែលត្រូវបានកំណត់ជាតំបន់មានមុខងារសម្រាប់បម្រើឱ្យការកម្សាន្ត ជាអាទិ៍តំបន់ផ្កាថ្ម ស្មៅសមុទ្រ តំបន់ព្រៃលិចទឹក ព្រៃកោងកាង បឹងធម្មជាតិ។

**ការធ្វើនេសាទខ្នាតតូច** សំដៅដល់ការធ្វើនេសាទជាលក្ខណៈគ្រួសារឬប្រពៃណី ដោយប្រើឧបករណ៍នេសាទខ្នាតតូចឬនាវាខ្នាតតូចរួមផ្សំជាមួយឧបករណ៍ខ្នាតតូច ជាអាទិ៍លប សន្ទូច ថ្នង សៃយ៉ឺន ទ្រូ តុម។

**ការធ្វើនេសាទខ្នាតមធ្យម** សំដៅដល់ការធ្វើនេសាទដោយប្រើឧបករណ៍នេសាទខ្នាតមធ្យមឬនាវានេសាទខ្នាតមធ្យមឬនាវាខ្នាតតូចរួមផ្សំជាមួយឧបករណ៍ខ្នាតមធ្យម ជាអាទិ៍អួន ម៉ាញ់ នាម អួនអូសនៅសមុទ្រ អួនទិត អួនកាកឹម។

**ការធ្វើនេសាទខ្នាតធំ** សំដៅដល់ការធ្វើនេសាទដោយប្រើឧបករណ៍នេសាទខ្នាតធំឬនាវានេសាទខ្នាតធំឬនាវាខ្នាតមធ្យមរួមផ្សំជាមួយឧបករណ៍ខ្នាតធំ ជាអាទិ៍ដាយត្រី ដាយបង្កង អួនអូសនៅសមុទ្រប្រើនាវាកម្លាំងលើសពី៥០០(ប្រាំរយ)សេះ។

**ការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ(IUU)** សំដៅដល់សកម្មភាពនេសាទដែលផ្ទុយនឹងវិធានការគ្រប់គ្រងនិងអភិរក្សថ្នាក់ជាតិឬអន្តរជាតិ ដូចខាងក្រោម៖

១- **ការធ្វើនេសាទខុសច្បាប់** សំដៅដល់សកម្មភាពដែល៖

- ប្រព្រឹត្តដោយនាវាជាតិឬនាវាបរទេសក្នុងដែនយុត្តាធិការជាតិ ដោយគ្មានការអនុញ្ញាតឬប្រព្រឹត្តផ្ទុយនឹងច្បាប់និងបទប្បញ្ញត្តិជាតិ

- ប្រព្រឹត្តដោយនាវាបំពាក់ទង់ជាតិនៃរដ្ឋភាគីនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ដែលផ្ទុយនឹងវិធានការគ្រប់គ្រងនិងអភិរក្សនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ដែលរដ្ឋនោះជាភាគី ឬផ្ទុយនឹងបទប្បញ្ញត្តិអន្តរជាតិពាក់ព័ន្ធ

- ប្រព្រឹត្តផ្ទុយនឹងច្បាប់ជាតិឬកាតព្វកិច្ចអន្តរជាតិ រួមទាំងការប្រព្រឹត្តធ្វើឡើងដោយរដ្ឋដែលមានកិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ។

២- **ការធ្វើនេសាទគ្មានរបាយការណ៍** សំដៅដល់សកម្មភាពនេសាទដែល៖

- ប្រព្រឹត្តក្នុងដែនយុត្តាធិការជាតិ ដោយមិនបានរាយការណ៍ឬរាយការណ៍មិនត្រឹមត្រូវជូនអាជ្ញាធរមានសមត្ថកិច្ច ដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តជាតិ

- ប្រព្រឹត្តក្នុងដែនសមត្ថកិច្ចនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ដោយមិនបានរាយការណ៍ឬរាយការណ៍មិនត្រឹមត្រូវ ដែលផ្ទុយនឹងនីតិវិធីនៃការរាយការណ៍របស់អង្គការនោះ។

៣- **ការធ្វើនេសាទគ្មានបញ្ញត្តិ** សំដៅដល់សកម្មភាពនេសាទដែល៖

- ប្រព្រឹត្តក្នុងតំបន់នៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ដោយនាវានេសាទគ្មានសញ្ជាតិឬនាវាបំពាក់ទង់ជាតិនៃរដ្ឋមិនមែនជាភាគីនៃអង្គការនោះឬក្រុមហ៊ុននេសាទ ដោយសកម្មភាពនេសាទនោះប្រព្រឹត្តផ្ទុយនឹងវិធានការគ្រប់គ្រងនិងអភិរក្សនៃអង្គការនោះ

- ប្រព្រឹត្តក្នុងតំបន់ណាមួយដែលមិនមានវិធានការគ្រប់គ្រងឬអភិរក្សផលស្តុកត្រី ឬការធ្វើនេសាទនោះមិនស្របនឹងការទទួលខុសត្រូវរបស់រដ្ឋក្នុងការអភិរក្សធនធានជលផលសមុទ្រមានជីវិតដែលស្ថិតក្រោមច្បាប់អន្តរជាតិ។

**ការធ្វើនេសាទរួមផ្សំដោយរបាំង** សំដៅដល់ការធ្វើនេសាទដោយប្រើឧបករណ៍លប លបណ ឬវ៉ារ ឬលូ ឬឡុក រួមផ្សំជាមួយរបាំងព្រួល ឬរបាំងសាច់អួន។



## ផ្នែកទី២
## ការអង្កេត ការតាមដាន និងការត្រួតពិនិត្យ

**មាត្រា៤៨ .-**

បុគ្គលដែលប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ឬតំបន់ក្រៅដែនយុត្តាធិការជាតិ ត្រូវដាក់ស្លាកសញ្ញាសម្គាល់និងកំណត់អត្តសញ្ញាណនាវាឱ្យបានច្បាស់លាស់ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤៩ .-**

បុគ្គលដែលប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាអាចធ្វើសកម្មភាពបាន លុះត្រាតែដាក់សញ្ញាសម្គាល់អត្តសញ្ញាណឧបករណ៍នេសាទ។

លក្ខណៈបច្ចេកទេសកំណត់សញ្ញាសម្គាល់អត្តសញ្ញាណឧបករណ៍នេសាទត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៥០ .-**

បុគ្គលដែលធ្វើការនេសាទខ្នាតមធ្យមឬខ្នាតធំដែលមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ត្រូវកត់ត្រានូវទិន្នន័យ ស្ថិតិ និងព័ត៌មានអំពីតំបន់នេសាទ រយៈពេលនេសាទ ផលនេសាទ និងឧបករណ៍នេសាទក្នុងសៀវភៅស្ថិតិផលនេសាទនិងត្រូវផ្តល់ជូនមន្ត្រីអធិការកិច្ចជលផល តាមពេលវេលាកំណត់។

បុគ្គលដែលប្រើនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំដែលមានលិខិតអនុញ្ញាតឱ្យធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ត្រូវកត់ត្រាព័ត៌មានអំពីសកម្មភាពនៃការវេចខ្ចប់ កែច្នៃ ផ្ទេរ ឬការដឹកជញ្ជូនផល ផលិតផលជលផលរួមទាំងការផ្តល់សេវាកម្មនាវិក ប្រេងឥន្ធនៈ និងការផ្គត់ផ្គង់ផ្សេងទៀតក្នុងសៀវភៅសកម្មភាពពាក់ព័ន្ធនឹងការនេសាទ និងត្រូវផ្តល់ជូនមន្ត្រីអធិការកិច្ចជលផលតាមពេលវេលាកំណត់។

**មាត្រា៥១ .-**

នាយនាវានេសាទធ្វើការនេសាទខ្នាតមធ្យមឬខ្នាតធំដែលមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ត្រូវ៖

១- រក្សាទុកសៀវភៅស្ថិតិផលនេសាទតាមនាវានិងត្រូវកត់ត្រាព័ត៌មានជាភាសាខ្មែរឬអង់គ្លេស។

២- ថែរក្សាសៀវភៅស្ថិតិផលនេសាទនិងត្រូវបង្ហាញដល់មន្ត្រីអធិការកិច្ចជលផលឬអ្នកសង្កេតការណ៍តាមការស្នើសុំ ដើម្បីត្រួតពិនិត្យឬធ្វើអធិការកិច្ច។

៣- ប្រគល់សៀវភៅស្ថិតិផលនេសាទជូនមន្ត្រីអធិការកិច្ចជលផល បន្ទាប់ពីបញ្ចប់ការឡើងផលនេសាទ។

នាយនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំដែលមានលិខិតអនុញ្ញាតឱ្យធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ត្រូវ៖

១- រក្សាទុកសៀវភៅសកម្មភាពពាក់ព័ន្ធនឹងការនេសាទតាមនាវា និងត្រូវកត់ត្រាព័ត៌មានជាភាសាខ្មែរឬអង់គ្លេស។

២- ថែរក្សាសៀវភៅសកម្មភាពពាក់ព័ន្ធនឹងការនេសាទ និងត្រូវបង្ហាញដល់មន្ត្រីអធិការកិច្ចជលផលឬអ្នកសង្កេតការណ៍តាមការស្នើសុំ ដើម្បីត្រួតពិនិត្យឬធ្វើអធិការកិច្ច។

៣- ប្រគល់សៀវភៅសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ជូនមន្ត្រីអធិការកិច្ចជលផលបន្ទាប់ពីបញ្ចប់សកម្មភាព។

**មាត្រា៥២ .-**

អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវបង្កើតប្រព័ន្ធទិន្នន័យ ដោយពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ ម្ចាស់កន្លែងឡើងផល ផលិតផលជលផលឯកជន អ្នកនេសាទ ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យពីការធ្វើនេសាទ។

**មាត្រា៥៣ .-**

អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវតម្រូវឱ្យប្រតិបត្តិករនាវាបរទេសដែលធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់ដែលបានកំណត់ មានអ្នកសង្កេតការណ៍នៅលើនាវា។

អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវបង្កើតកម្មវិធីសម្រាប់អ្នកសង្កេតការណ៍ក្នុងការប្រមូល កត់ត្រា និងរាយការណ៍អំពីព័ត៌មានជាក់លាក់ ដើម្បីតាមដានសកម្មភាពនេសាទ និងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

នីតិវិធីសម្រាប់ការអនុវត្តមុខងារនៃអ្នកសង្កេតការណ៍និងប្រតិបត្តិករ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៥៤ .-**

បុគ្គលដែលប្រើនាវាខ្នាតមធ្យមឬខ្នាតធំត្រូវបំពាក់ឧបករណ៍តាមដាននាវានៅលើនាវានេសាទនិងរក្សាឱ្យមានដំណើរការជាប្រចាំក្នុងការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជានិងតំបន់ក្រៅដែនយុត្តាធិការជាតិ។

ការកំណត់ឧបករណ៍តាមដាននាវា លក្ខខណ្ឌបច្ចេកទេស និងវិធានសម្រាប់ប្រតិបត្តិការនៃប្រព័ន្ធតាមដាននាវាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៥៥ .-**

នាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទដែលមិនធ្លាប់ប្រើកំពង់ផែនេសាទកម្ពុជា ដើម្បីឡើងផល ផលិតផលជលផល ផ្ទេរ វេចខ្ចប់ ឬកែច្នៃផលនេសាទ ឬប្រើសេវាកំពង់ផែនេសាទ ជាអាទិ៍ការចាក់ប្រេងឥន្ធនៈ ការផ្គត់ផ្គង់ ការជួសជុល និងការថែទាំ អាចអនុញ្ញាតឱ្យប្រើកំពង់ផែនេសាទបាន លុះត្រាតែ៖

១- ចូលកំពង់ផែនេសាទដែលបានកំណត់សម្រាប់នាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ ដែលបានផ្សព្វផ្សាយជាសាធារណៈ។

២- ប្រតិបត្តិករនាវាបានជូនដំណឹងមុន២៤(ម្ភៃបួន)ម៉ោងដល់អង្គភាពជំនាញទទួលបន្ទុកជលផល។

៣- ប្រតិបត្តិករនាវាបង្ហាញលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែដល់មន្ត្រីអធិការកិច្ចជលផល នៅពេលនាវាមកដល់។

**មាត្រា៥៦ .-**

មន្ត្រីអធិការកិច្ចជលផលត្រូវបដិសេធនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទក្នុងការចូលចតនៅកំពង់ផែនេសាទកម្ពុជា ក្នុងករណី៖

១- មានភស្តុតាងបញ្ជាក់ថា នាវានោះបានធ្វើការនេសាទឬធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

២- នាវាមានក្នុងបញ្ជីឈ្មោះនាវាខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។



## ឧបសម្ព័ន្ធទី១នៃច្បាប់ស្តីពីជលផល

## សទ្ទានុក្រម

**កន្លែងនេសាទតាមឆ្នេរ** សំដៅដល់តំបន់គ្រប់គ្រងជលផលសមុទ្រដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ខ្សែបន្ទាត់ដែលមានជម្រៅទឹកក្នុងរង្វង់២០ម៉ែត្រ។ លក្ខណវិនិច្ឆ័យនៃការកំណត់កន្លែងនេសាទតាមឆ្នេរ ត្រូវកំណត់ដោយអនុក្រឹត្យដូចមានចែងក្នុងមាត្រា១៤។

**កន្លែងកំណត់ការប្រើឧបករណ៍នេសាទជាក់លាក់** សំដៅដល់កន្លែងនេសាទសម្រាប់ការដេញថ្លៃជាសាធារណៈ ដូលឬវិនិយោគ ដោយកំណត់អំពីប្រភេទឧបករណ៍នេសាទ ជាអាទិ៍ដាយត្រី ដាយត្រីលេញ ដាយបង្កង។

**កន្លែងនេសាទសមុទ្រក្រៅ** សំដៅដល់តំបន់គ្រប់គ្រងជលផលសមុទ្រដែលលាតសន្ធឹងពីព្រំប្រទល់ខាងក្រៅនៃកន្លែងនេសាទតាមឆ្នេរ រហូតដល់ព្រំប្រទល់ខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខនៃព្រះរាជាណាចក្រកម្ពុជា។

**កន្លែងនេសាទសាធារណៈ** សំដៅដល់តំបន់គ្រប់គ្រងជលផលដែលស្ថិតនៅក្រៅកន្លែងអភិរក្សជលផល កន្លែងសហគមន៍នេសាទ កន្លែងអភិវឌ្ឍន៍វារីវប្បកម្ម កន្លែងនេសាទកំណត់ឧបករណ៍នេសាទជាក់លាក់ កន្លែងគ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គនៃតំបន់គ្រប់គ្រងជលផលទឹកសាប។

**កន្លែងសហគមន៍នេសាទ** សំដៅដល់ផ្នែកមួយនៃតំបន់គ្រប់គ្រងជលផលដែលបានកំណត់ព្រំប្រទល់ និងទំហំច្បាស់លាស់ សម្រាប់ប្រគល់ជូនសហគមន៍នេសាទប្រើប្រាស់ផ្តាច់មុខ ប្រកបដោយនិរន្តរភាព។ ក្នុងកន្លែងសហគមន៍នេសាទ មានជាអាទិ៍កន្លែងនេសាទ កន្លែងអភិរក្ស កន្លែងការពារជលផល កន្លែងជម្រកសុវត្ថិភាពជលផល កន្លែងវារីវប្បកម្ម។

**កន្លែងជម្រកសុវត្ថិភាពជលផល** សំដៅដល់ផ្នែកមួយនៃកន្លែងសហគមន៍នេសាទ សម្រាប់ការពារវារីសត្វមួយឬច្រើនប្រភេទក្នុងរយៈពេលកំណត់ជាក់លាក់នៃវដ្ដជីវិត ដើម្បីធានានិរន្តរភាពនៃផលស្តុក។

**កន្លែងការពារជលផល** សំដៅដល់ផ្នែកមួយនៃកន្លែងសហគមន៍នេសាទនៅជាប់ឬក្បែរកន្លែងអភិរក្សជលផលដែលអនុញ្ញាតឱ្យធ្វើតែការនេសាទខ្នាតតូចៗ។ កន្លែងការពារជលផលមានតួនាទីជាតំបន់ទ្រនាប់។

**កន្លែងអភិរក្សជលផល** សំដៅដល់ផ្នែកមួយនៃតំបន់គ្រប់គ្រងជលផលដែលត្រូវបានកំណត់ព្រំប្រទល់និងទំហំច្បាស់លាស់ សម្រាប់វារីសត្វពងកូន រីកធំធាត់ ឬលូតលាស់ ពុំអនុញ្ញាតឱ្យធ្វើការនេសាទគ្រប់ប្រភេទនិងធ្វើសកម្មភាពដែលប៉ះពាល់ធនធានវារីជាតិ លើកលែងតែការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល។

**កន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ** សំដៅដល់ផ្នែកមួយនៃតំបន់គ្រប់គ្រងជលផលដែលត្រូវបានកំណត់ជាតំបន់ស្នូលនៃតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ក្នុងខេត្តក្រចេះនិងខេត្តស្ទឹងត្រែង។

**កន្លែងការពារសត្វផ្សោតទន្លេមេគង្គ** សំដៅដល់ផ្នែកមួយនៃតំបន់គ្រប់គ្រងជលផលដែលត្រូវបានកំណត់ជាតំបន់ទ្រនាប់នៃតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ក្នុងខេត្តក្រចេះនិងខេត្តស្ទឹងត្រែង។

**កន្លែងឡើងផល ផលិតផលជលផល** សំដៅដល់ផែបណ្ដោតឬផែនៅជាប់មាត់ទឹកដែលជាកន្លែងលើកដាក់ ផ្ទេរ ឬឡើងផល ផលិតផលជលផល ពីនាវាមកកាន់ដីគោក។

**ការធ្វើនេសាទ** សំដៅដល់ការចាប់ ការរុករក ការទាក់ទាញ ការទាញយក ការស្វែងរក ឬការប្រមូលផលវារីសត្វ ដោយប្រើឧបករណ៍ សម្ភារៈ ឬមធ្យោបាយនេសាទផ្សេងៗ។

បទប្បញ្ញត្តិដែលកំណត់អំពីបទល្មើសជលផលដូចមានកំណត់នៅក្នុងច្បាប់ស្តីពីជលផលដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃច្បាប់នេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលច្បាប់នេះចូលជាធរមាន លើកលែងតែការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ។

ថ្ងៃ សៅរ៍ ៣កើត ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២៥

ការល.២៥០៦.៩៩៦

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**



ទោះបីមានករណីដូចក្នុងកថាខណ្ឌទី១នៃមាត្រានេះក៏ដោយ មន្ត្រីអធិការកិច្ចជលផលមានសិទ្ធិឱ្យនាវាខាងលើចូលចតក្នុងកំពង់ផែនេសាទកម្ពុជា ក្នុងករណី៖

១- ធ្វើអធិការកិច្ចនាវានិងចាត់វិធានការសមស្របអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទនិងសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

២- មានឧបទ្ទវហេតុឬប្រធានសក្តិ នាវាអាចចូលចតនៅកំពង់ផែនេសាទកម្ពុជាក្នុងអំឡុងពេលជាក់ស្តែង។

មន្ត្រីអធិការកិច្ចជលផលសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធអាចហាមឃាត់នាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទចូលកំពង់ផែនេសាទកម្ពុជា ក្នុងករណីដែលនាវានោះអនុវត្តផ្ទុយនឹងវិធានការគ្រប់គ្រងនិងអភិរក្សនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬរដ្ឋម្ចាស់ទង់ជាតិដែលមិនមែនជាសមាជិកឬជាភាគីដែលមិនសហការជាមួយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ លើកលែងតែពិនិត្យឃើញថាផលនេសាទនៅលើនាវាបានមកពីការធ្វើនេសាទស្របតាមវិធានការគ្រប់គ្រងនិងអភិរក្ស។

**មាត្រា៥៧ .-**

អង្គភាពជំនាញទទួលបន្ទុកជលផលអាចបដិសេធនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទដែលមិនធ្លាប់ប្រើកំពង់ផែនេសាទកម្ពុជា ដើម្បីឡើងផល ផលិតផលជលផល ផ្ទេរ វេចខ្ចប់ ឬកែច្នៃផលនេសាទ ឬប្រើសេវាកំពង់ផែនេសាទ ជាអាទិ៍ការចាក់ប្រេងឥន្ធនៈ ការផ្គត់ផ្គង់ ការជួសជុល និងការថែទាំក្នុងករណី៖

១- នាវាមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទដែលចេញដោយរដ្ឋម្ចាស់ទង់ជាតិហួសសុពលភាព។

២- នាវាគ្មានលិខិតអនុញ្ញាតឱ្យធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ស្ថិតក្រោមច្បាប់នេះ។

៣- មានភស្តុតាងបង្ហាញថា ផលនេសាទនៅលើនាវាបានពីការធ្វើនេសាទល្មើសនឹងលក្ខខណ្ឌតម្រូវក្នុងដែនយុត្តាធិការនៃរដ្ឋម្ចាស់ឆ្នេរ។

៤- រដ្ឋម្ចាស់ទង់ជាតិនៃនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ មិនបានឆ្លើយតបតាមការស្នើសុំពីអង្គភាពជំនាញទទួលបន្ទុកជលផល ទោះជាផលនេសាទនៅលើនាវាបានពីការនេសាទតាមលក្ខខណ្ឌតម្រូវនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ក៏ដោយ។

៥- មានហេតុផលច្បាស់លាស់ថា នាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទបានធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិឬធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ លើកលែងតែបុគ្គលដែលប្រើនាវាមានភស្តុតាងបង្ហាញថាបានធ្វើសកម្មភាពត្រឹមត្រូវតាមវិធានការគ្រប់គ្រងនិងអភិរក្ស។

ទោះបីមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ អង្គភាពជំនាញទទួលបន្ទុកជលផលអាចអនុញ្ញាតឱ្យនាវាប្រើសេវាកំពង់ផែនេសាទសម្រាប់សុវត្ថិភាពនាវានិងសុខភាពនាវិក ដែលជាតម្រូវការចាំបាច់ឬចោលកាកសំណល់លើនាវានៅទីតាំងដែលបានកំណត់។

**មាត្រា៥៨ .-**

ករណីនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ ត្រូវបានបដិសេធការចូលចតនៅកំពង់ផែនេសាទឬប្រើសេវាកំពង់ផែនេសាទកម្ពុជា អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវជូនដំណឹងទៅរដ្ឋម្ចាស់ទង់ជាតិ ឬរដ្ឋម្ចាស់ឆ្នេរជាបន្ទាន់ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ឬអង្គការអន្តរជាតិដែលពាក់ព័ន្ធតាមការចាំបាច់សមស្រប។

ករណីនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ ត្រូវបានបដិសេធការប្រើសេវាកំពង់ផែនេសាទកម្ពុជា បន្ទាប់ពីការធ្វើអធិការកិច្ច អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវបញ្ជូនរបាយការណ៍អធិការកិច្ចទៅរដ្ឋម្ចាស់ទង់ជាតិ ក្នុងករណីចាំបាច់ត្រូវបញ្ជូនរបាយការណ៍ទៅរដ្ឋម្ចាស់ឆ្នេរ អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ អង្គការអន្តរជាតិដែលពាក់ព័ន្ធ ឬរដ្ឋសញ្ជាតិនៃនាយនាវា។

**មាត្រា៥៩ .-**

មន្ត្រីអធិការកិច្ចជលផលត្រូវផ្ដល់អាទិភាពក្នុងពេលធ្វើអធិការកិច្ចចំពោះនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទនៅកំពង់ផែនេសាទកម្ពុជា ដូចខាងក្រោម៖

១- នាវាធ្លាប់បានបដិសេធការចូលចតឬប្រើកំពង់ផែនេសាទដែលស្ថិតក្រោមដែនសមត្ថកិច្ចនៃរដ្ឋផ្សេងទៀត។

២- ការស្នើសុំធ្វើអធិការកិច្ចពីរដ្ឋដទៃឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ពិសេសការស្នើសុំដែលមានភស្តុតាងបញ្ជាក់ថានាវាជាប់ពាក់ព័ន្ធនឹងការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៣- នាវាផ្សេងទៀតដែលមានមូលហេតុច្បាស់លាស់សង្ស័យជាប់ពាក់ព័ន្ធនឹងការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៤- នាវាដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦០ .-**

ក្នុងពេលធ្វើអធិការកិច្ចលើនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទនៅកំពង់ផែនេសាទកម្ពុជា មន្ត្រីអធិការកិច្ចជលផល ត្រូវ៖

១- បង្ហាញឯកសារកំណត់អត្តសញ្ញាណដល់នាយនាវា មុនពេលធ្វើអធិការកិច្ច។

២- អញ្ជើញតំណាងរដ្ឋម្ចាស់ទង់ជាតិនៃនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ ចូលរួមធ្វើអធិការកិច្ចក្នុងករណីចាំបាច់។

៣- ចៀសវាងការរំខាននាយនាវាក្នុងការទាក់ទងទៅអាជ្ញាធរនៃរដ្ឋម្ចាស់ទង់ជាតិ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

៤- ត្រួតពិនិត្យគ្រប់ទីកន្លែងនៃនាវា ដូចជាផលនេសាទ ឧបករណ៍នេសាទ សម្ភារៈ និងឯកសារ ឬកំណត់ត្រាលើនាវា ដែលពាក់ព័ន្ធក្នុងការបញ្ជាក់ពីសកម្មភាពអនុវត្តស្របតាមផែនការគ្រប់គ្រងនិងអភិរក្ស។

៥- តម្រូវឱ្យនាយនាវា សហការ និងសម្របសម្រួលក្នុងការផ្ដល់ព័ត៌មានចាំបាច់ បង្ហាញសម្ភារៈ និងឯកសារពាក់ព័ន្ធតាមការតម្រូវ។

៦- ខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាព ចៀសវាងនូវការពន្យារពេល ការរំខាន ឬបង្កការលំបាកដែលនាំឱ្យប៉ះពាល់ដល់គុណភាពផលនេសាទនៅលើនាវា។

៧- ខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាពក្នុងទំនាក់ទំនងជាមួយនាយនាវាឬនាវិកសំខាន់ៗ ក្នុងករណីចាំបាច់ត្រូវមានអ្នកបកប្រែ។

៨- អនុវត្តការធ្វើអធិការកិច្ចដោយយុត្តិធម៌ តម្លាភាព និងមិនរើសអើង។

**មាត្រា៦១ .-**

បុគ្គលដែលប្រើនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទនៅក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ៖



៧- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ខ្លឹមសារ របៀបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា១០០ .-**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៩៦ មាត្រា៩៧ និងមាត្រា៩៨នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា៩៦នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០ (ប្រាំរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា៩៧នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ទៅ១ ០០០ ០០០ ០០០ (មួយពាន់លាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា៩៨នៃច្បាប់នេះ។

**មាត្រា១០១ .-**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៣នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីអំពើដែលកំណត់ថាជាបទល្មើសមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**មាត្រា១០២ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធច្បាប់ស្ដីពីជលផល ដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៣ .-**

បុគ្គលដែលកំពុងកាន់កាប់ឬប្រើប្រាស់លិខិតគតិយុត្តស្ថិតក្រោមច្បាប់ស្ដីពីជលផលដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវបន្តអនុវត្តរហូតដល់ផុតសុពលភាព។ ការស្នើសុំបន្តសុពលភាពឬការស្នើសុំថ្មី ត្រូវអនុវត្តស្របតាមច្បាប់នេះ។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា១០៤ .-**

ច្បាប់ស្ដីពីជលផលដែលមានមុនការចូលជាធរមាននៃច្បាប់នេះ ត្រូវបាត់បង់អានុភាពនិងត្រូវជំនួសដោយច្បាប់នេះ។

៦- ធ្វើការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ឬប្រើចំណីវារីសត្វ ឱសថវារីសត្វ ដែលមានសារធាតុជំរុញការលូតលាស់ខុសប្រក្រតី ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ។

៧- ទន្រ្ទាន ហ៊ុមព័ទ្ធកាន់កាប់ ដុត កាប់ឆ្ការ រុករាន ឈូសឆាយ ឬផ្តួលរំលំព្រៃលិចទឹកឬព្រៃកោងកាងចាប់ពី១(មួយ)ហិកតាឡើងទៅ។

៨- បង្កឱ្យភ្លើងឆេះព្រៃលិចទឹកឬព្រៃកោងកាងដោយចេតនា។

៩- ផ្លាស់ប្តូរ រំកិល ជីកកប់ ឬបំផ្លាញបង្គោលព្រំប្រទល់នៃតំបន់គ្រប់គ្រងជលផល។

១០- គាស់ កកាយ ឬយកក្រួស ថ្ម ដី ខ្សាច់ ឬរ៉ែក្នុងកន្លែងអភិរក្សជលផល។

១១- ធ្វើការនេសាទដែលបំផ្លាញមច្ឆជាតិ ធនធានជលផល ឬប្រព័ន្ធអេកូឡូស៊ីជលផលក្នុងតំបន់គ្រប់គ្រងជលផល។

១២- ប្រមូលផល ទិញ លក់ ធ្វើអំណោយ ឬចែកចាយនូវផល ផលិតផលវារីវប្បកម្មដោយដឹងថាមានជំងឺ ឬមានជាតិពុល ឬមានផ្ទុកសំណល់គីមីលើសកម្រិតកំណត់ ដែលប៉ះពាល់ដល់សុខភាពសាធារណៈ។

១៣- ក្លែងបន្លំប្រភពដើម អត្តសញ្ញាណ ឈ្មោះពាណិជ្ជកម្ម សម្បកវេចខ្ចប់ សារធាតុឬសមាសធាតុផ្សំរបស់ចំណីវារីសត្វឬឱសថវារីសត្វ ប្រើប្រាស់ក្នុងការធ្វើវារីវប្បកម្ម។

ចំពោះបទល្មើសដូចមានចែងក្នុងចំណុចទី៥នៃមាត្រា៩៧នៃច្បាប់នេះ ហើយដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ត្រូវកំណត់ថាជាបទល្មើសពុករលួយដែលត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយទៅតុលាការ។

ការស៊ើបអង្កេតបទល្មើសពុករលួយក្នុងវិស័យជលផល និងការកសាងសំណុំរឿងពុករលួយនៅក្នុងវិស័យនេះទៅតុលាការ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ ស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

**មាត្រា៩៨ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយដែលធ្វើសកម្មភាពបំផ្លាញធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផល ហើយបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានឬប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់គ្រប់គ្រងជលផល។

**មាត្រា៩៩ .-**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា៩៦ មាត្រា៩៧ និងមាត្រា៩៨ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចខាងក្រោម៖

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

២- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣- ការរឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលម្អទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

៦- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។



១- ត្រូវសហការឱ្យបានពេញលេញក្នុងការធ្វើអធិការកិច្ចនៅកំពង់ផែនេសាទនៃរដ្ឋដទៃ តាមច្បាប់និងនីតិវិធីនៃរដ្ឋម្ចាស់ផ្ទែរ។

២- ហាមឡើង វេចខ្ចប់ ឬកែច្នៃផល ផលិតផលជលផលឬប្រើសេវាផ្សេងៗនៅកំពង់ផែនេសាទនៃរដ្ឋដទៃ ដែលទទួលស្គាល់ដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ក្នុងករណីអនុវត្តផ្ទុយនឹងលិខិតុបករណ៍ថ្នាក់តំបន់ ឬអន្តរជាតិពាក់ព័ន្ធនឹងវិធានការរដ្ឋម្ចាស់កំពង់ផែនេសាទ។

នៅពេលមានមូលហេតុច្បាស់លាស់សង្ស័យនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទ បានធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិនិងកំពុងស្វែងរកការចូលចតឬកំពុងស្ថិតក្នុងកំពង់ផែនេសាទនៃរដ្ឋដទៃ អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវស្នើរដ្ឋនោះធ្វើអធិការកិច្ចឬចាត់វិធានការស្របតាមលិខិតុបករណ៍ថ្នាក់តំបន់ឬអន្តរជាតិ។

នៅពេលមានមូលហេតុច្បាស់លាស់សង្ស័យនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទ បានធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវស៊ើបអង្កេតឱ្យបានពេញលេញនិងឆាប់រហ័ស។ ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់ ត្រូវចាត់វិធានការជាបន្ទាន់ ដោយអនុលោមតាមច្បាប់នេះ។

## ផ្នែកទី៣
## ការឡើងនិងការផ្ទេរផល ផលិតផលជលផល

**មាត្រា៦២ .-**

ការឡើងផល ផលិតផលជលផលដោយនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំត្រូវធ្វើនៅកំពង់ផែនេសាទឬកន្លែងឡើងផល ផលិតផលជលផល ដែលត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះការឡើងផល ផលិតផលជលផលដោយនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតតូច អាចប្រព្រឹត្តទៅនៅគ្រប់ទីកន្លែង លើកលែងតែកន្លែងហាមឃាត់ដែលកំណត់ដោយអង្គភាពជំនាញទទួលបន្ទុកជលផលនិងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ប្រតិបត្តិករនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំបរទេស បន្ទាប់ពីបានឡើងផល ផលិតផលជលផល ត្រូវធ្វើប្រតិវេទន៍អំពីការឡើងផល ផលិតផលជលផល ជូនអង្គភាពជំនាញទទួលបន្ទុកជលផល។

ការកំណត់កំពង់ផែនេសាទ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

បែបបទនិងនីតិវិធីនៃការប្រើកំពង់ផែនេសាទឬកន្លែងឡើងផល ផលិតផលជលផលដោយនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៦៣ .-**

ការផ្ទេរផល ផលិតផលជលផលដោយនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាឬក្នុងកំពង់ផែនេសាទឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជាត្រូវហាមឃាត់ លើកលែងតែនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទមានលិខិតអនុញ្ញាតឱ្យផ្ទេរពីអង្គភាពជំនាញទទួលបន្ទុកជលផល។

ការផ្ទេរផល ផលិតផលជលផលពីនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិឬក្នុងកំពង់ផែនេសាទបរទេស ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល និងត្រូវផ្ទេរនៅ៖

១- សមុទ្រអន្តរជាតិដែលស្ថិតក្រោមការគ្រប់គ្រងនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ អនុលោមតាមលក្ខខណ្ឌនៃការផ្ទេរដែលកំណត់ដោយអង្គការថ្នាក់តំបន់នោះ។

២- សមុទ្រដែលស្ថិតក្នុងដែនអធិបតេយ្យឬក្រោមយុត្តាធិការនៃរដ្ឋដទៃ លុះត្រាតែមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃរដ្ឋនោះ។

៣- កំពង់ផែនេសាទបរទេសដែលត្រូវបានកំណត់សម្រាប់នាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទបរទេស។

ប្រតិបត្តិករនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទកម្ពុជាឬបរទេស បន្ទាប់ពីបញ្ចប់ការផ្ទេរផល ផលិតផលជលផល ត្រូវធ្វើប្រតិវេទន៍អំពីការផ្ទេរផល ផលិតផលជលផល ជូនអង្គភាពជំនាញទទួលបន្ទុកជលផល។

នីតិវិធី លក្ខខណ្ឌតម្រូវ និងបែបបទនៃការធ្វើប្រតិវេទន៍អំពីការឡើងឬផ្ទេរផល ផលិតផលជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ផ្នែកទី៤
## ការការពារបុគ្គលដែលធ្វើការងារនៅលើនាវានេសាទ និងនាវាពាក់ព័ន្ធនឹងការនេសាទ

**មាត្រា៦៤ .-**

បុគ្គលដែលប្រើនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ អាចជ្រើសរើសពលរដ្ឋខ្មែរឱ្យធ្វើការលើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬតំបន់ក្រៅដែនយុត្តាធិការជាតិ និងត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជានិងអនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

**មាត្រា៦៥ .-**

បុគ្គលដែលប្រើនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទ អាចជ្រើសរើសបុគ្គលឱ្យធ្វើការលើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាឬតំបន់ក្រៅដែនយុត្តាធិការជាតិ និងត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជានិងអនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

## ជំពូកទី៨
## សហគមន៍នេសាទ

**មាត្រា៦៦ .-**

ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាស្នើសុំបង្កើតសហគមន៍នេសាទ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តដើម្បីទទួលសិទ្ធិគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលក្នុងតំបន់គ្រប់គ្រងជលផលនៅតាមមូលដ្ឋានប្រកបដោយនិរន្តរភាពសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

សហគមន៍នេសាទ គឺជាសហគមន៍កសិកម្មដែលត្រូវបានបង្កើតនិងគ្រប់គ្រងស្របតាមច្បាប់ស្តីពីសហគមន៍កសិកម្ម។



ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

ករណីជនប្រព្រឹត្តបទល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចជលផលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងនិងបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីជាធរមាន។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃនៃការពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីដែលបានចូលរួមក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា៩៦ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយ ដូចខាងក្រោម៖

១- បំផ្លាញស្មៅសមុទ្រឬផ្កាថ្ម។

២- ទន្រ្ទាន ហ៊ុមព័ទ្ធកាន់កាប់ ដុត កាប់ឆ្ការ រុករាន ឈូសឆាយ ឬផ្តួលរំលំព្រៃលិចទឹកឬព្រៃកោងកាងតិចជាង១(មួយ)ហិកតា។

៣- ធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកឬព្រៃកោងកាង។

៤- ធ្វើអាជីវកម្មផល ផលិតផលជលផលដែលក្លែងបន្លំ។

៥- បង្ហូរឬបោះចោលនូវសារធាតុពុល កាកសំណល់វារីវប្បកម្ម ឱសថវារីសត្វ ឬឧបករណ៍សម្ភារៈទៅក្នុងតំបន់គ្រប់គ្រងជលផល ដោយគ្មានការអនុញ្ញាត ឬពុំបានកែលម្អគុណភាពទឹកស្របតាមបទបញ្ជាបច្ចេកទេស ឬលក្ខខណ្ឌតម្រូវ ដែលបណ្តាលឱ្យពុលឬបង្កគ្រោះថ្នាក់ដល់វារីសត្វឬវារីរុក្ខជាតិ។

៦- រក្សាទុកឧបករណ៍ឆក់ត្រីក្នុងគោលបំណងដើម្បីធ្វើការនេសាទខុសច្បាប់។

**មាត្រា៩៧ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយ ដូចខាងក្រោម៖

១- ធ្វើការនេសាទខ្នាតមធ្យមឬខ្នាតធំក្នុងកន្លែងអភិរក្សជលផលឬកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

២- ធ្វើការនេសាទដោយបូម បាច ពង្រីងផ្នែកណាមួយនៃតំបន់គ្រប់គ្រងជលផល ដែលអាចបង្កឬធ្វើឱ្យមហន្តរាយដល់ធនធានជលផលដែលជាប្រយោជន៍សាធារណៈ។

៣- ធ្វើការនេសាទដោយប្រើឧបករណ៍ឆក់ គ្រឿងផ្ទុះ ឬសារធាតុពុល។

៤- ផលិត ទិញ ឬលក់ឧបករណ៍ឆក់ត្រី។

៥- លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ផ្ទេរ ឬបញ្ចាំកន្លែងសហគមន៍នេសាទ ឬយកកន្លែងសហគមន៍នេសាទធ្វើជាកម្មសិទ្ធិឯកជន។

ហាមឃាត់ សារធាតុពុលគ្រប់ប្រភេទ សារធាតុគីមីហាមឃាត់ និងអាវុធឬជាតិផ្ទុះដែលជាមធ្យោបាយសម្រាប់ការប្រព្រឹត្តបទល្មើសជលផល និងផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសជលផល។

## ជំពូកទី១៣
## ទោសប្បញ្ញត្តិ

**មាត្រា៩៣ .-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

**មាត្រា៩៤ .-**

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកសកម្មភាព ការព្យួរ ឬការដកហូតជាបណ្តោះអាសន្នវិញ្ញាបនបត្រឬលិខិតអនុញ្ញាត
- ការលុបចោលឬការដកហូតវិញ្ញាបនបត្រឬលិខិតអនុញ្ញាត
- ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬអង្គភាពជំនាញទទួលបន្ទុកជលផល ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច។

អំពើល្មើសដែលត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មានសិទ្ធិប្តឹងទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសម្រេចលើពាក្យប្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹងតវ៉ា។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីច្បាប់ជាធរមាន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។ ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលនោះទេ។

**មាត្រា៩៥ .-**

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះបទល្មើស ដូចមានចែងក្នុងច្បាប់នេះ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ត្រីអធិការកិច្ចជលផលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។



**មាត្រា៦៧ .-**

អង្គភាពជំនាញទទួលបន្ទុកជលផល មានភារកិច្ចកំណត់ព្រំប្រទល់កន្លែងសហគមន៍នេសាទឱ្យមានទំហំសមស្រប ផ្អែកតាមសក្តានុពលនៃធនធានជលផលនិងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ដោយមានការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីស្នើសុំសេចក្តីសម្រេចបង្កើតកន្លែងសហគមន៍នេសាទពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អង្គភាពជំនាញទទួលបន្ទុកជលផលមានសិទ្ធិចេញលិខិតប្រគល់កន្លែងសហគមន៍នេសាទ ឱ្យសហគមន៍ប្រើប្រាស់ផ្តាច់មុខ ស្របតាមលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់កន្លែងសហគមន៍នេសាទ។ ក្នុងករណីចាំបាច់អង្គភាពជំនាញទទួលបន្ទុកជលផលមានសិទ្ធិដកហូតកន្លែងសហគមន៍នេសាទមកវិញ។

**មាត្រា៦៨ .-**

សហគមន៍នេសាទត្រូវប្រើប្រាស់កន្លែងសហគមន៍នេសាទរបស់ខ្លួនឱ្យមាននិរន្តរភាព ស្របតាមលក្ខខណ្ឌចែងក្នុងលិខិតប្រគល់កន្លែងសហគមន៍នេសាទដែលកំណត់ដោយអង្គភាពជំនាញទទួលបន្ទុកជលផល។

អង្គភាពជំនាញទទួលបន្ទុកជលផល ត្រូវតាមដាននិងត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់កន្លែងសហគមន៍នេសាទ។

**មាត្រា៦៩ .-**

សហគមន៍នេសាទគ្មានសិទ្ធិលក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ផ្ទេរ ឬបញ្ចាំកន្លែងសហគមន៍នេសាទ ឬយកកន្លែងសហគមន៍នេសាទធ្វើជាកម្មសិទ្ធិឯកជន ឬចុះកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងកន្លែងសហគមន៍នេសាទជាមួយបុគ្គលណាមួយឡើយ។

ចំពោះការសិក្សាស្រាវជ្រាវឬការអភិវឌ្ឍក្នុងកន្លែងសហគមន៍នេសាទ សហគមន៍នេសាទត្រូវស្នើសុំអង្គភាពជំនាញទទួលបន្ទុកជលផលធ្វើជាតំណាងក្នុងការចុះកិច្ចព្រមព្រៀងជាមួយបុគ្គល បន្ទាប់ពីមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៩
## ការគ្រប់គ្រងវារីវប្បកម្ម

**មាត្រា៧០ .-**

ការធ្វើវារីវប្បកម្មទឹកសាបនិងសមុទ្រត្រូវបានចាត់ថ្នាក់ជាខ្នាតតូច ខ្នាតមធ្យម ឬខ្នាតធំ។

ការធ្វើវារីវប្បកម្មខ្នាតតូចមិនតម្រូវឱ្យមានលិខិតអនុញ្ញាត លើកលែងតែការបង្កាត់ឬការភ្ញាស់វារីជាតពូជថ្មីនាំចូល ប៉ុន្តែត្រូវចុះបញ្ជី គោរពតាមបទបញ្ញាបច្ចេកទេសនិងលក្ខខណ្ឌតម្រូវ និងផ្តល់ព័ត៌មានអំពីសកម្មភាពមកអង្គភាពជំនាញទទួលបន្ទុកជលផល ដើម្បីកត់ត្រាក្នុងប្រព័ន្ធទិន្នន័យ។

បុគ្គលដែលធ្វើវារីវប្បកម្មខ្នាតមធ្យមឬខ្នាតធំ ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល និងត្រូវគោរពតាមបទបញ្ញាបច្ចេកទេសនិងលក្ខខណ្ឌតម្រូវ ព្រមទាំងលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

បទបញ្ញាបច្ចេកទេសនិងលក្ខខណ្ឌតម្រូវនៃការធ្វើវារីវប្បកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ចំណាត់ថ្នាក់វារីវប្បកម្មនិងនីតិវិធីនៃការផ្តល់ ការផ្ទេរ និងការបញ្ចប់លិខិតអនុញ្ញាតធ្វើវារីវប្បកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៧១ .–**

ការធ្វើវារីវប្បកម្មវារិជាតដែលជាប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល។

ការធ្វើពាណិជ្ជកម្មនាំចូល នាំចេញប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ដែលបានមកពីការធ្វើវារីវប្បកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងត្រូវអនុលោមតាមអនុសញ្ញាសាយតេសចំពោះប្រភេទដែលមានក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស។

នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត សម្រាប់ធ្វើវារីវប្បកម្មនៃប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៧២ .–**

ការវិនិយោគវារីវប្បកម្មខ្នាតមធ្យមនិងខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលដែលមិនមែនជាកម្មសិទ្ធិឯកជន ត្រូវមានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧៣ .–**

បុគ្គលដែលធ្វើវារីវប្បកម្មខ្នាតមធ្យមនិងខ្នាតធំ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ធានាអនាម័យ គុណភាព និងសុវត្ថិភាពនៃការធ្វើវារីវប្បកម្ម។

២- ប្រើពូជវារិជាតដែលមានគុណភាពសម្រាប់ការធ្វើវារីវប្បកម្ម។

៣- កត់ត្រារាល់ស្ថិតិវារីវប្បកម្មនៅក្នុងសៀវភៅស្ថិតិវារីវប្បកម្មនិងរាយការណ៍ជូនមន្ត្រីជំនាញទទួលបន្ទុកជលផល តាមពេលកំណត់។

៤- រាយការណ៍និងផ្តល់សំណាកវារិជាតដែលសង្ស័យមានជំងឺឬមានជំងឺឆ្លងឬរាតត្បាតជូនមន្ត្រីជំនាញទទួលបន្ទុកជលផល ដើម្បីពិសោធស្រាវជ្រាវបញ្ជាក់ពីសុខភាព គុណភាព សុវត្ថិភាព និងរោគសាស្ត្រ។

៥- គោរពតាមបទបញ្ជាបច្ចេកទេសនិងលក្ខខណ្ឌតម្រូវនៃការធ្វើវារីវប្បកម្ម។

៦- គោរពតាមលក្ខខណ្ឌតម្រូវផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៧៤ .–**

បុគ្គលដែលនាំចូល នាំចេញ និងនាំឆ្លងកាត់ពូជវារិជាត ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល។

រាល់ការនាំចូលនិងការនាំឆ្លងកាត់ពូជវារិជាតត្រូវមានវិញ្ញាបនបត្រសុខភាព។

រាល់ការនាំឆ្លងកាត់ពូជវារិជាតត្រូវអនុវត្តតាមលក្ខខណ្ឌ ក្នុងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ សន្ធិសញ្ញា អនុសញ្ញា និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រសុខភាព លិខិតអនុញ្ញាតឱ្យនាំចូល នាំចេញ និងនាំឆ្លងកាត់ពូជវារិជាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៧៥ .–**

បុគ្គលដែលផលិត នាំចូល នាំឆ្លងកាត់ ធ្វើសន្និធិ វេចខ្ចប់ជាថ្មី ឬផ្គត់ផ្គង់ចែកចាយ ឬលក់ដុំ លក់រាយចំណីវារីសត្វឬឱសថវារីសត្វ ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល។



ಽ

និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេត ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា៨៨ .–**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ មន្ត្រីអធិការកិច្ចជលផលត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចជលផល ត្រូវកំណត់ដោយអនុក្រឹត្យ។

ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៨៩ .–**

មន្ត្រីអធិការកិច្ចជលផលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិប្រើប្រាស់អាវុធស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៩០ .–**

វត្ថុចាប់យកនៃបទល្មើសជលផលដែលមានចែងក្នុងច្បាប់នេះ មានជាអាទិ៍៖

១- ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ កូនឬពងវារីសត្វ ឧបករណ៍នេសាទហាមឃាត់ គ្រឿងផ្ទុះ សារធាតុពុលគ្រប់ប្រភេទ។

២- ផល ផលិតផលជលផល សំណាកវារិជាត ឱសថវារីសត្វឬចំណីវារីសត្វ និងសារធាតុគីមីហាមឃាត់។

៣- មធ្យោបាយដឹកជញ្ជូន គ្រឿងចក្រ ឧបករណ៍សម្ភារៈបរិក្ខារ ឬឧបករណ៍អេឡិចត្រូនិកដែលជាមធ្យោបាយសម្រាប់ការប្រព្រឹត្តបទល្មើសជលផល។

៤- អាវុធឬជាតិផ្ទុះដែលជាមធ្យោបាយសម្រាប់ការប្រព្រឹត្តបទល្មើសជលផល។

៥- ផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសជលផល។

វត្ថុចាប់យកដែលមិនអាចរក្សាទុកបានយូរ ដែលអាចខូចខាតភ្លាមៗ ឬខូចគុណភាព ឬបង្កមហន្តរាយធ្ងន់ធ្ងរដល់ធនធានជលផល ឬបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ មន្ត្រីអធិការកិច្ចជលផលមានសិទ្ធិព្យាបាលលែង បំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈ ដោយមានកំណត់ហេតុត្រឹមត្រូវនិងមានការយល់ព្រមពីព្រះរាជអាជ្ញា។

**មាត្រា៩១ .–**

ការចំណាយលើវត្ថុវិភាគនិងសេវាកម្មវិភាគ ការចំណាយលើការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុចាប់យក ត្រូវជាបន្ទុករបស់ជនល្មើស។ ក្នុងករណីមិនស្គាល់អត្តសញ្ញាណជនល្មើស រាល់ការចំណាយជាបន្ទុករបស់រដ្ឋ។

**មាត្រា៩២ .–**

វត្ថុចាប់យកដែលពាក់ព័ន្ធនឹងបទល្មើសជលផលដែលមានចែងក្នុងច្បាប់នេះ អាចត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋ ឬបំផ្លាញចោល ឬប្រគល់ឱ្យអ្នកកាន់កាប់វត្ថុឬម្ចាស់ដើមវិញ ដោយអនុវត្តស្របតាមច្បាប់នេះ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

មន្ត្រីអធិការកិច្ចជលផលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវប្រគល់វត្ថុចាប់យកឱ្យអ្នកកាន់កាប់វត្ថុឬម្ចាស់ដើមវិញ បន្ទាប់ពីប្រាក់ពិន័យអន្តរការណ៍ត្រូវបានបង់រួចនិងមានការយល់ព្រមពីព្រះរាជអាជ្ញា លើកលែងតែវត្ថុចាប់យកដែលជាប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ កូនឬពងវារីសត្វ ឧបករណ៍នេសាទ



ಽ

របស់ខ្លួន។ ការចាត់តាំងមន្ត្រីអធិការកិច្ចជលផលត្រូវធ្វើដោយផ្អែកលើលក្ខណសម្បត្តិដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មន្ត្រីអធិការកិច្ចជលផលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសជលផលដូចមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវលើកសំណើសុំផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចជលផលថ្នាក់ក្រោមជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មករដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តនីតិវិធីបន្ត។

ការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌និងបែបបទនិងនីតិវិធីនៃការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ ចំពោះមន្ត្រីអធិការកិច្ចជលផល ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ការកំណត់ដែនសមត្ថកិច្ចសម្រាប់មន្ត្រីអធិការកិច្ចជលផលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយសេចក្ដីសម្រេចផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌។

**មាត្រា៨៥ .–**

មន្ត្រីអធិការកិច្ចជលផលមានសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យនិងតាមដានការធ្វើនេសាទនិងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ឬការធ្វើវារីវប្បកម្ម ឬការធ្វើអាជីវកម្ម ឬការដឹកជញ្ជូន នាំចេញ នាំចូល និងនាំឆ្លងកាត់ផល ផលិតផលជលផល ឬការផលិត នាំចេញ នាំចូល នាំឆ្លងកាត់ ធ្វើសន្និធិ វេចខ្ចប់ជាថ្មី ឬផ្គត់ផ្គង់ ចែកចាយ លក់ដុំ លក់រាយ នូវចំណីវារីសត្វឬឱសថវារីសត្វ ព្រមទាំងគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សុខភាពវារីជាត សំណល់ឱសថវារីសត្វ ឬការប្រើប្រាស់ឯកសារពាក់ព័ន្ធ
- ចាត់វិធានការផ្អាកជាបណ្ដោះអាសន្ន ចំពោះការធ្វើនេសាទនិងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ឬការធ្វើវារីវប្បកម្ម ឬការធ្វើអាជីវកម្មផល ផលិតផលជលផល ឬការដឹកជញ្ជូន នាំចេញ នាំចូល និងនាំឆ្លងកាត់ផល ផលិតផលជលផល ឬការផលិត នាំចេញ នាំចូល នាំឆ្លងកាត់ ធ្វើសន្និធិ វេចខ្ចប់ជាថ្មី ឬផ្គត់ផ្គង់ ចែកចាយ លក់ដុំ លក់រាយ នូវចំណីវារីសត្វឬឱសថវារីសត្វ រួចរាយការណ៍ឱ្យបានឆាប់ជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានវិធានការបន្ត។

បែបបទនិងនីតិវិធីសម្រាប់ធ្វើអធិការកិច្ចជលផលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៨៦ .–**

មន្ត្រីអធិការកិច្ចជលផលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ អាចប្រើប្រាស់សិទ្ធិអំណាចស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាអាទិ៍៖

- ឆែកឆេរ ចាប់យកវត្ថុតាង កោះហៅ ឃុំខ្លួន និងអនុវត្តកិច្ចនីតិវិធីផ្សេងទៀត
- ថែរក្សានិងគ្រប់គ្រងវត្ថុចាប់យកដែលពាក់ព័ន្ធនឹងបទល្មើសជលផលជាបណ្ដោះអាសន្ន
- ប្រគល់វត្ថុចាប់យកឱ្យអ្នកកាន់កាប់វត្ថុឬម្ចាស់ដើមវិញ
- អនុវត្តការពិន័យអន្តរការណ៍ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ចាត់វិធានការផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ។

**មាត្រា៨៧ .–**

ក្នុងប្រតិបត្តិការពិនិត្យបទល្មើស មន្ត្រីអធិការកិច្ចជលផលដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងអាចស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ



រាល់ការផលិតឬនាំចូលប្រភេទចំណីវារីសត្វឬឱសថវារីសត្វ ត្រូវចុះបញ្ជីដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់។ ចំណីវារីសត្វឬឱសថវារីសត្វគ្រប់ប្រភេទដែលស្នើចុះបញ្ជី ត្រូវឆ្លងកាត់ការធ្វើវិភាគ ផ្ទៀងផ្ទាត់សមាសធាតុឬសារធាតុសកម្មនៅមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ចំណីវារីសត្វឬឱសថវារីសត្វដែលមានទិន្នន័យមិនគ្រប់គ្រាន់សម្រាប់វាយតម្លៃលើសំណើសុំចុះបញ្ជី តម្រូវឱ្យធ្វើការសាកល្បងប្រសិទ្ធភាពនិងសុវត្ថិភាពនៅមន្ទីរពិសោធន៍ឬស្ថានីយពិសោធន៍ដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវកំណត់ពិធីសារសាកល្បងប្រសិទ្ធភាពនិងគោលការណ៍ណែនាំសម្រាប់វិភាគចំណីវារីសត្វឬឱសថវារីសត្វ។

នីតិវិធីនៃការផ្ដល់លិខិតអនុញ្ញាតនិងការគ្រប់គ្រង ការផលិត នាំចូល នាំឆ្លងកាត់ ធ្វើសន្និធិ វេចខ្ចប់ជាថ្មី ផ្គត់ផ្គង់ ចែកចាយ ឬលក់ដុំ លក់រាយ និងការចុះបញ្ជីចំណីវារីសត្វឬឱសថវារីសត្វ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៧៦ .–**

ហាមឃាត់សកម្មភាពដូចខាងក្រោម៖

១- ការលែងវារីសត្វគ្រប់ប្រភេទដែលមិនមែនជាពូជក្នុងប្រទេសចូលទៅក្នុងតំបន់គ្រប់គ្រងជលផល លើកលែងតែមានការអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល។

២- ការផលិត ការនាំចូល ការនាំចេញ ការចែកចាយ ឬការប្រើចំណីវារីសត្វឬឱសថវារីសត្វដែលមានសារធាតុជំរុញការលូតលាស់ខុសប្រក្រតី ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ។

៣- ការបង្ហូរឬការបោះចោលនូវសារធាតុពុល កាកសំណល់វារីវប្បកម្ម ឱសថវារីសត្វ និងឧបករណ៍សម្ភារៈទៅក្នុងតំបន់គ្រប់គ្រងជលផលដោយគ្មានការអនុញ្ញាតនិងពុំបានកែលម្អគុណភាពទឹកស្របតាមបទបញ្ជាបច្ចេកទេស និងលក្ខខណ្ឌតម្រូវ ដែលបណ្ដាលឱ្យពុលឬបង្កគ្រោះថ្នាក់ដល់វារីសត្វឬវារីរុក្ខជាតិ។

៤- ការប្រើកូនត្រីឬកូនវារីសត្វផ្សេងទៀតដែលបានពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ដើម្បីផលិតជាម្សៅត្រី ខ្លាញ់ត្រី ឬចំណីវារីសត្វក្នុងការធ្វើវារីវប្បកម្ម។

៥- ការប្រមូលផល ការទិញ ការលក់ ការធ្វើអំណោយ ឬការចែកចាយនូវផល ផលិតផលវារីវប្បកម្មដែលមានជំងឺ ឬមានជាតិពុល ឬមានផ្ទុកសំណល់គីមីលើសកម្រិតកំណត់។

៦- ការក្លែងបន្លំប្រភពដើម អត្តសញ្ញាណ ឈ្មោះពាណិជ្ជកម្ម សម្បករវេចខ្ចប់ សារធាតុឬសមាសធាតុផ្សំរបស់ចំណីវារីសត្វឬឱសថវារីសត្វដែលប្រើក្នុងការធ្វើវារីវប្បកម្ម។

៧- ការធ្វើវារីវប្បកម្មប្រភេទវារីជាតហាមឃាត់។

**មាត្រា៧៧ .–**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញសេចក្ដីប្រកាសស្ដីពីការឆ្លងឬការរាតត្បាតជំងឺវារីសត្វណាមួយ តាមសំណើរបស់អង្គភាពជំនាញទទួលបន្ទុកជលផល។

អង្គភាពជំនាញទទួលបន្ទុកជលផលត្រូវផ្សព្វផ្សាយនិងចាត់វិធានការបង្ការ ការទប់ស្កាត់ និងការការពារការឆ្លងឬការរាតត្បាតជំងឺវារីសត្វ។

ករណីចាំបាច់ ពេលកើតមានជំងឺធ្ងន់ធ្ងរចំពោះវារីសត្វដែលបណ្ដាលឱ្យប៉ះពាល់សុខភាពសាធារណៈ និងបរិស្ថានធ្ងន់ធ្ងរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួងសុខាភិបាលនិងក្រសួងបរិស្ថាន ដើម្បីចាត់វិធានការបង្ការនិងទប់ស្កាត់ការរីករាលដាល។

## ជំពូកទី១០
## ការគ្រប់គ្រងផល ផលិតផលជលផល

**មាត្រា៧៨ .-**

អង្គភាពជំនាញទទួលបន្ទុកជលផល មានភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងនិងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផល ផលិតផលជលផលនៃការធ្វើអាជីវកម្មផល ផលិតផលជលផល ការដឹកជញ្ជូន ការនាំចេញ ការនាំចូល និងការនាំឆ្លងកាត់។

នីតិវិធីនិងលក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលនៃការធ្វើអាជីវកម្មផល ផលិតផលជលផល ការដឹកជញ្ជូន ការនាំចេញ ការនាំចូល និងការនាំឆ្លងកាត់ជាលក្ខណៈពាណិជ្ជកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៧៩ .-**

បុគ្គលដែលធ្វើអាជីវកម្មផល ផលិតផលជលផល ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល លើកលែងតែអាជីវកម្មលក្ខណៈគ្រួសារ ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត។

ចំពោះប្រភេទផល ផលិតផលជលផលកំពុងរងគ្រោះថ្នាក់ដែលស្ថិតក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស ត្រូវអនុលោមតាមអនុសញ្ញាសាយតេសនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា៨០ .-**

បុគ្គលដែលធ្វើអាជីវកម្មផល ផលិតផលជលផល ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

១- អនុវត្តគោលការណ៍អនាម័យល្អនិងផលិតកម្មល្អ។

២- ធានាស្តង់ដាអនាម័យនិងសុវត្ថិភាពអាហារ។

៣- ធានាការវេចខ្ចប់និងដាក់ស្លាកសញ្ញាពាណិជ្ជកម្មលើផល ផលិតផលជលផលឱ្យត្រឹមត្រូវ។

៤- មានសៀវភៅតាមដានការអង្កេតដានផល ផលិតផលជលផល។

៥- ទទួលខុសត្រូវលើផល ផលិតផលជលផលដែលគ្មានសុវត្ថិភាព។

៦- រាយការណ៍អំពីផល ផលិតផលជលផលដែលគ្មានសុវត្ថិភាព មកអង្គភាពជំនាញទទួលបន្ទុកជលផល ឬមន្ត្រីជំនាញទទួលបន្ទុកជលផលមានសមត្ថកិច្ចជិតបំផុត ដើម្បីចាត់វិធានការតាមនីតិវិធី។

៧- អនុវត្តលក្ខខណ្ឌផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៨១ .-**

បុគ្គលដែលនាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល វិញ្ញាបនបត្របញ្ជាក់ប្រភពដើម និងវិញ្ញាបនបត្រសុខភាពស្របតាមនីតិវិធីនិងលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល។

បុគ្គលដែលនាំចេញនិងនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពទទួលបន្ទុកជលផល ចំពោះផលិតផលដែលកំណត់ក្នុងបញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់និងវិញ្ញាបនបត្រសុខភាព អនុលោមតាមលក្ខខណ្ឌតម្រូវពីប្រទេសនាំចូល។

ចំពោះការនាំចេញ នាំចូល និងនាំឆ្លងកាត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ដែលស្ថិតក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស ត្រូវមានលិខិតអនុញ្ញាតពីអង្គភាពជំនាញទទួលបន្ទុកជលផល អនុលោមតាមអនុសញ្ញាសាយតេសនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។



ការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតអនុញ្ញាត។

រាល់ការនាំឆ្លងកាត់ផល ផលិតផលជលផល ត្រូវអនុវត្តលក្ខខណ្ឌដូចមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញឆ្លងកាត់ ឬអនុសញ្ញា កិច្ចព្រមព្រៀង និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

**មាត្រា៨២ .-**

ហាមឃាត់សកម្មភាពដូចខាងក្រោម៖

១- ក្លែងបន្លំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬឯកសារពាក់ព័ន្ធដែលតម្រូវដោយច្បាប់នេះ។

២- ក្លែងបន្លំលទ្ធផលវិភាគ សំណាកវិភាគ លទ្ធផលរោគវិនិច្ឆ័យសុខភាពវារិជាត។

៣- ធ្វើអាជីវកម្មផល ផលិតផលជលផលដែលក្លែងបន្លំ គ្មានអនាម័យ ឬខូចគុណភាព។

៤- ធ្វើអាជីវកម្ម ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលដែលបានពីការធ្វើនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៥- ធ្វើអាជីវកម្ម ដឹកជញ្ជូន នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌដែលកំណត់ក្នុងលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល។

៦- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬវិញ្ញាបនបត្រសុខភាព។

៧- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មដោយគ្មានលិខិតអនុញ្ញាតចំពោះផលិតផលដែលកំណត់ក្នុងបញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់។

៨- ប្រើសារជាតុបន្ថែមលើសកម្រិតអនុញ្ញាតឬសារជាតុគីមីហាមឃាត់លើផល ផលិតផលជលផលនិងផលិតកម្មវារីវប្បកម្ម ដូចមានចែងក្នុងលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល។

៩- ប្រមូលទិញ លក់ ធ្វើអំណោយ ឬចែកចាយផល ផលិតផលជលផលដែលផ្ទុកសំណល់គីមីលើសកម្រិតកំណត់។

## ជំពូកទី១១
## កម្រៃសេវាសាធារណៈ

**មាត្រា៨៣ .-**

បុគ្គលដែលស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រសម្រាប់សកម្មភាពអាជីវកម្ម សេវាកម្មពាក់ព័ន្ធនឹងជលផល ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ មានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈ។

កម្រៃសេវាសាធារណៈតាមប្រភេទនីមួយៗត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១២
## អធិការកិច្ចជលផល

**មាត្រា៨៤ .-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់តាំងឱ្យមានមន្ត្រីអធិការកិច្ចជលផលថ្នាក់ជាតិ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់តាំងឱ្យមានមន្ត្រីអធិការកិច្ចជលផលថ្នាក់ក្រោមជាតិ ក្នុងដែនសមត្ថកិច្ច